**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# ឯកសារ

# ស្តីពី

# ការពន្យារពេលមួយឆ្នាំនៃផអព

**ខែវិច្ឆិកា ឆ្នាំ២០១៣**

# អារម្ភកថា

ផែនការអនុវត្តបីឆ្នាំសម្រាប់ឆ្នាំ២០១១-២០១៣ (**ផអ៣**) គឺផែនការអនុវត្តដំណាក់កាលដំបូងនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលបំណងសំខាន់នៃ**ផអ៣** គឺផ្តោតទៅលើការអភិវឌ្ឍគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងកំណែទម្រង់ ព្រមទាំងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ការរៀបចំបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រព័ន្ធផ្ទេរមូលនិធិ និងគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការជំរុញឲ្យមានការផ្ទេរមុខងារជាបណ្តើរៗទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតជាសំខាន់ទៅលើរដ្ឋបាលថ្នាក់ក្រុង ស្រុក។

ជាមួយគ្នានេះដែរ ការខិតខំបន្តពង្រឹងនូវស្វ័យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងយន្តការត្រួតពិនិត្យមើលពីលើនូវការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាចំណុចស្នូលដែលត្រូវផ្តោតការយកចិត្តទុកដាក់នៅក្នុងផអ៣នេះផងដែរ។ ការសម្រេចបាននូវគោលបំណងខាងលើទាំងនេះ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការរៀបចំផែនការអនុវត្តបីឆ្នាំបន្តបន្ទាប់ទៀតនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

យ៉ាងណាមិញ យោងតាមស្ថានភាពនៃការអនុវត្តជាក់ស្តែងក្នុងរយៈពេល៣ឆ្នាំកន្លងមកនេះ និងផ្អែកតាមលទ្ធផលនៃការសិក្សាវាយតម្លៃពាក់កណ្តាលអាណត្តិនៃផអ៣ ព្រមទាំងការឯកភាពពីភាគីពាក់ព័ន្ធនានា បានតម្រូវឲ្យធ្វើការពន្យារពេលនៃការអនុវត្ត**ផអ៣**រយៈពេល១ឆ្នាំបន្ថែមទៀតដល់ឆ្នាំ២០១៤ ដើម្បីធានា ដល់ការសម្រេចបាននូវគោលបំណងនៃ**ផអ៣** ក្នុងន័យបង្កើតបាននូវមូលដ្ឋានគ្រឹះដ៏រឹងមាំនៃកិច្ចដំណើរការកំណែទម្រង់មុននឹងឈានទៅដល់ការរៀបចំ និងអនុវត្តដំណាក់កាលបីឆ្នាំបន្ទាប់នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្នុងន័យនេះ ឯកសារពន្យារពេលនៃផអ៣នេះ ត្រូវបានរៀបចំឡើងដោយមានការចូលរួម ការពិគ្រោះយោបល់ និងការឯកភាពគ្នារវាងតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល តាមរយៈការរៀបចំឲ្យមានកិច្ចប្រជុំពិភាក្សា និងសិក្ខាសាលាពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយតួអង្គពាក់ព័ន្ធនានាអស់រយៈពេលប្រមាណជាង៣ខែនៃឆមាសទី២ឆ្នាំ២០១៣ ដើម្បីធានាដល់ការចូលរួមរបស់ស្ថាប័ននានាក្នុងការរៀបចំតាក់តែង និងអនុវត្តកិច្ចដំណើរការកំណែទម្រង់ក្នុងដំណាក់កាលនៃការពន្យារពេលបន្ថែមនេះប្រកបដោយប្រសិទ្ធភាព និងភាពម្ចាស់ការ។

ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែកយ៉ាងសកម្មពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ជាពិសេសចំពោះការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍ដល់កិច្ចដំណើរការកំណែទម្រង់ ហើយខ្ញុំក៏មានសេចក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ឯកសារពន្យារពេលផអ៣នេះនឹងត្រូវប្រើប្រាស់ជាឯកសារយុទ្ធសាស្ត្រ

សម្រាប់ធ្វើជាផែនទីបង្ហាញផ្លូវក្នុងការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៤ប្រកបដោយភាពប្រាកដប្រជា ដោយមានការកំណត់ឲ្យបានច្បាស់លាស់នូវសកម្មភាព វិធីសាស្ត្រ ប្រភពធនធាន និងក្របខ័ណ្ឌពេលវេលាជាក់លាក់ ដើម្បីខិតខំប្រឹងប្រែងរួមគ្នាសម្រេចឲ្យបាននូវលទ្ធផលរំពឹងទុកនានាដែលបានឯកភាពគ្នា។

ទន្ទឹមគ្នានេះដែរ ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះរាល់ការចូលរួមយោបល់ក្នុងន័យស្ថាបនា ដើម្បីកែលំអ និងជំរុញការអនុវត្តកិច្ចដំណើរការក្នុងចិរវេលានៃការពន្យារពេលនៃផអ៣ ក្នុងឆ្នាំ២០១៤ឲ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**

# មាតិកា

**ផ្នែកទី១ ÷ សេចក្តីផ្តើម**............................................................................................................**១**
១.១. គោលបំណង..........................................................................................................................១
១.២. កិច្ចដំណើរការរៀបចំ.............................................................................................................២
១.៣. រចនាសម្ព័ន្ធឯកសារ................................................................................................................២
**ផ្នែកទី២ ÷ សេចក្តីសង្ខេបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា**.......................................................... **៤**
២.១. វឌ្ឍនភាព...............................................................................................................................៤
២.២. បញ្ហាប្រឈម.........................................................................................................................៥
**ផ្នែកទី៣ ÷ ក្របខ័ណ្ឌកម្មវិធី និងលទ្ធផលរំពឹងទុកជាអាទិភាព** .................................................................**៧**
៣.១. ក្របខ័ណ្ឌនៃកម្មវិធី ................................................................................................................ ៧
៣.២. លទ្ធផលរំពឹងទុកជាអាទិភាពនានាសម្រាប់ឆ្នាំ២០១៤........................................................................ ៧
**ផ្នែកទី៤ ÷ ការគ្រប់គ្រងកម្មវិធី** ........................................................................................................... **១១**
៤.១. ចិរវេលា ............................................................................................................................. ១១
៤.២. ការសម្របសម្រួល ការគ្រប់គ្រង និងការអនុវត្តកម្មវិធី ...................................................................... ១១
៤.៣. ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីនានា ........................ ១១
៤.៤. ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ..........................................១២
៤.៥. ការគ្រប់គ្រង និងការតាមដានការអនុវត្តកម្មវិធី...............................................................................១២
៤.៦. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស .....................................................................................១៣
៤.៧. ការគ្រប់គ្រងហិរញ្ញវត្ថុ.............................................................................................................. ១៤
៤.៨. ការងារអន្តរវិស័យ..................................................................................................................... ១៤
**ផ្នែកទី៥ ÷ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ**.....................................................................................**១៧**
**ផ្នែកទី៦ ÷ ថវិកាប៉ាន់ស្មានសម្រាប់កម្មវិធី និងប្រភពហិរញ្ញប្បទាន**.................................................................. **១៩**
៦.១. ថវិកាផអ៣សម្រាប់អភិវឌ្ឍសមត្ថភាព ប្រតិបត្តិការកម្មវិធី និងជំនួយបច្ចេកទេស ...................... ១៩
៦.២. ការផ្តល់ហិរញ្ញប្បទានតាមរយៈយន្តការនៃការផ្ទេរហិរញ្ញប្បទានអន្តររដ្ឋបាលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ.........................................................................................................................២០
៦.៣. គម្រោងពាក់ព័ន្ធផ្សេងៗទៀត (គម្រោងដាច់ដោយឡែក) .......................................................................២០
៦.៤. ថវិកាចំណាយ និងការផ្តល់ហិរញ្ញប្បទានរបស់ផអ៣ ឆ្នាំ២០១៤ (កញ្ចប់ថវិការួម).....................២១
**ផ្នែកទី៧ ÷ ដំណើរការរៀបចំផអ៣ ដំណាក់កាលបន្ទាប់**............................................................................ **២៣**
**ផ្នែកទី៨ ÷ ការធ្វើបច្ចុប្បន្នភាពលើការសន្មត និងហានិភ័យនានារបស់ ផអ៣** .........................................**២៤**

# ផ្នែកទី១

# សេចក្តីផ្តើម

ផែនការអនុវត្តបីឆ្នាំដំបូង២០១១-២០១៣ (ផអ៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្តដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០។ គោលដៅសំខាន់នៃផអ៣ គឺការរៀបចំបង្កើតឲ្យបាននូវមូលដ្ឋានគ្រឹះនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ ដែលក្នុងនោះរួមមាន **ការអភិវឌ្ឍស្ថាប័ន ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ យន្តការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ព្រមទាំង**យន្តការគាំទ្រ និងត្រួតពិនិត្យដល់ការបំពេញមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**។

ជាទូទៅ ទោះបីផអ៣ត្រូវបានរៀបចំឡើងដោយមានការចូលរួមពិភាក្សា ពិគ្រោះយោបល់ជាច្រើនជាមួយនឹងអ្នកពាក់ព័ន្ធនានាមែនពិត ក៏ប៉ុន្តែឯកសារនេះត្រូវបានក្រុមវាយតម្លៃពាក់កណ្តាលអាណត្តិនៃផអ៣បានកត់សម្គាល់ឃើញថា ឯកសារនេះបានកំណត់នូវលទ្ធផលរំពឹងទុកយ៉ាងច្រើនប្រកបដោយភាពមហិច្ឆតា បើប្រៀបធៀបនឹងក្របខ័ណ្ឌពេលវេលា៣ឆ្នាំដើម្បីសម្រេចនូវលទ្ធផលរំពឹងទុកទាំងនោះ។ ជាមួយគ្នានេះដែរ ដោយសារមានភាពចាំបាច់ក្នុងការរៀបចំនូវបែបផែនថ្មីនៃការគ្រប់គ្រងកម្មវិធី និងប្រព័ន្ធផ្ទេរធនធានសម្រាប់គាំទ្រដល់ការអនុវត្តផអ៣ អាស្រ័យហេតុនេះ ការចាប់ផ្តើមអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១ ដែលជាឆ្នាំដំបូងនៃការអនុវត្តផអ៣ ត្រូវបានពន្យារពេលរយៈពេល៦ខែ។ ក្រៅពីនេះ ការថយចុះនៃការផ្តល់ធនធានគាំទ្រប្រៀបធៀបទៅនឹងចំនួនធនធានដែលបានព្យាករណ៍សម្រាប់ការអនុវត្តផអ៣ ក៏ជាមូលហេតុសំខាន់មួយដែលនាំឲ្យពុំអាចសម្រេចបាននូវចំណុចដៅជាមូលដ្ឋានមួយចំនួនក្នុងដំណាក់កាល៣ឆ្នាំដំបូងនេះផងដែរ។

ដើម្បីធានាដល់ការសម្របសម្រួលការអនុវត្តក្នុងដំណាក់កាលដំបូងនេះ ឲ្យសម្រេចបាននូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ឈានទៅរៀបចំ និងអនុវត្តនូវផែនការអនុវត្ត៣ឆ្នាំដំណាក់កាលបន្ទាប់ ជម្រើសនៃការរៀបចំឲ្យមានការពន្យារពេលមួយឆ្នាំនៃការអនុវត្តផអ៣ដំណាក់កាលដំបូងនេះ ត្រូវបានលើកយកមកពិនិត្យ ពិភាក្សា និងមានការឯកភាពគ្នាពីគ្រប់អ្នកពាក់ព័ន្ធនានា។

## ១.១. គោលបំណង

ការពន្យារពេលនៃការអនុវត្តផអ៣រយៈពេលមួយឆ្នាំរហូតដល់ដំណាច់ឆ្នាំ២០១៤ មានគោលបំណងដូចខាងក្រោម ៖

- សម្រេចបាននូវលទ្ធផលរំពឹងទុកសំខាន់ៗនៃផអ៣ដោយផ្តោតការយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រទៅលើចំណុចដៅជាអាទិភាពនានាដែលជាមូលដ្ឋានគ្រឹះនៃកំណែទម្រង់
- ផ្តល់ឱកាសឲ្យមានការពិនិត្យមើលឡើងវិញនូវលទ្ធផលរំពឹងនានានិងដំណោះស្រាយនូវបញ្ហាប្រឈមសំខាន់ៗដែលបានជួបប្រទះក្នុងពេលអនុវត្តកន្លងមក

- មានពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រៀមរៀបចំឯកសារផអ៣ដំណាក់កាលបន្ទាប់។

## ១.២. កិច្ចដំណើរការរៀបចំ

ក្នុងកិច្ចដំណើរការរៀបចំឯកសារពន្យារពេលមួយឆ្នាំនៃផអ៣ លេខាធិការដ្ឋាន គ.ជ.អ.ប បានបង្កើតក្រុមការងារមួយ ព្រមទាំងបានជ្រើសរើសទីប្រឹក្សាជាតិរយៈពេលខ្លីមួយរូបផ្អែកតាមល័ក្ខខ័ណ្ឌការងារដែលមានការឯកភាពគ្នាជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីសម្របសម្រួលការរៀបចំតាក់តែងឯកសារនៃការពន្យារពេលអផ៣នេះ។

ក្នុងកិច្ចដំណើរការនេះ ក្រុមការងារបានរៀបចំជួបពិភាក្សា និងផ្លាស់ប្តូរយោបល់ជាមួយតំណាងក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីនានានៃផអ៣ តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាតាមជំហានសំខាន់ដូចខាងក្រោម ៖

- ការជួបពិគ្រោះយោបល់ដោយឡែកៗតាមក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីនីមួយៗ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងដំណើរការអនុវត្តផអ៣
- ការរៀបចំកិច្ចប្រជុំពិភាក្សាជាមួយស្ថាប័នអនុវត្តអនុកម្មវិធីនីមួយៗដើម្បីកំណត់ឬសគល់នៃបញ្ហានានា ដំណោះស្រាយ និងសកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០១៤
- ការរៀបចំសេចក្តីព្រាងបឋមនៃឯកសារពន្យារពេលផអ៣ ដោយផ្អែកលើលទ្ធផលដែលទទួលបានពីជំហាននានាខាងលើ
- ការរៀបចំសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងតំណាងដៃគូអភិវឌ្ឍន៍នានា ដើម្បីពិគ្រោះយោបល់ទៅលើសេចក្តីព្រាងបឋមនៃឯកសារពន្យារពេលផអ៣
- ការរៀបចំបញ្ចប់សេចក្តីព្រាងចុងក្រោយនៃឯកសារពន្យារពេលផអ៣ ដើម្បីដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត។

## ១.៣. រចនាសម្ព័ន្ធឯកសារ

ឯកសារពន្យារពេលមួយឆ្នាំនៃផអ៣ ត្រូវបានបែងចែកជា៨ផ្នែកដូចតទៅ ៖

- **ផ្នែកទី១** បរិយាយអំពីមូលហេតុ និងគោលបំណងនៃការពន្យាពេលមួយឆ្នាំនៃផអ៣ និងរចនាសម្ព័ន្ធនៃឯកសារពន្យារពេលផអ៣។
- **ផ្នែកទី២** បរិយាយសង្ខេបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមដែលបានជួបប្រទះក្នុងអំឡុងពេលនៃការអនុវត្តផអ៣។
- **ផ្នែកទី៣** បរិយាយអំពីក្របខ័ណ្ឌទូទៅនៃកម្មវិធី និងលទ្ធផលរំពឹងទុកជាអាទិភាពចំនួន១៣ដែលត្រូវផ្តោតការយកចិត្តទុកដាក់សម្រេចឲ្យបាននៅក្នុងឆ្នាំ២០១៤។
- **ផ្នែកទី៤** បរិយាយអំពីបែបផែននៅការគ្រប់គ្រងកម្មវិធី និងវិធានការនានាដែលត្រូវផ្តោតការយកចិត្តទុកដាក់ដោយស្ថាប័នអនុវត្តនានា ការពង្រឹងការអភិវឌ្ឍធនធានមនុស្ស និងការ

គ្រប់គ្រងហិរញ្ញវត្ថុរបស់កម្មវិធី ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តក្នុងឆ្នាំ២០១៤ រួមបញ្ចូលទាំងការគិតគូរដល់បញ្ហាអន្តរវិស័យដែលរួមមានបញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុផងដែរ។

- **ផ្នែកទី៥** បរិយាយអំពីការបន្តពង្រឹងបន្ថែមនូវយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដោយផ្តោតទៅលើការពង្រឹងប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារ ការតាមដាន និងវាយតម្លៃគោលនយោបាយ ការធ្វើសវនកម្ម និងអធិការកិច្ច ព្រមទាំងការពង្រឹងបន្ថែមនូវប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង។
- **ផ្នែកទី៦** បរិយាយអំពីស្ថានភាពហិរញ្ញវត្ថុនៃអផ៣ក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានថវិកាសម្រាប់ការអនុវត្តអផ៣ឆ្នាំ២០១៤។
- **ផ្នែកទី៧** បរិយាយអំពីកិច្ចការសំខាន់ៗ និងក្របខ័ណ្ឌពេលវេលាសម្រាប់ការរៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់។
- **ផ្នែកទី៨** ជាផ្នែកចុងបញ្ចប់នៃឯកសារនេះបរិយាយអំពីការធ្វើបច្ចុប្បន្នភាពនៃការសន្មត និងការកំណត់ឡើងវិញនូវកម្រិតនៃហានិភ័យ ព្រមទាំងវិធានការនានាដែលត្រូវផ្តោតការយកចិត្តទុកដាក់ដើម្បីកាត់បន្ថយនូវកម្រិតនៃហានិភ័យទាំងនោះ។

ដោយសារឯកសារនេះ គឺជាឯកសារពន្យារពេលមួយឆ្នាំនៃផអ៣ អាស្រ័យហេតុនេះ ឯកសារដើមផអ៣ឆ្នាំ២០១១-២០១៣ ដែលមានលក្ខណៈលម្អិត និងទូលំទូលាយនឹងនៅតែជាឯកសារគោលសំខាន់សម្រាប់ការអនុវត្តក្នុងឆ្នាំ២០១៤ដដែល។ យ៉ាងណាមិញ ឯកសារពន្យារពេលមួយឆ្នាំនៃផអ៣នេះ គ្រាន់តែឆ្លុះបញ្ចាំងនូវសកម្មភាពជាអាទិភាពសំខាន់ៗសម្រាប់អនុវត្តក្នុងឆ្នាំ២០១៤ប៉ុណ្ណោះ។

## ផ្នែកទី២

## សេចក្តីសង្ខេបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា

### ២.១. វឌ្ឍនភាព

ការអនុវត្តផអពក្នុងរយៈពេលកន្លងមក បានបង្កើតឲ្យមានសមិទ្ធផលសំខាន់ៗជាច្រើនដែលជាមូលដ្ឋានគ្រឹះសម្រាប់ការជំរុញដល់កិច្ចដំណើរការកំណែទម្រង់ប្រកបដោយភាពប្រាកដប្រជា ឆ្ពោះទៅកាន់គោលដៅអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យ។ រចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងវិញ ព្រមពេលជាមួយគ្នានេះដែរ មន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនេះ ហើយប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យក៏ត្រូវបានរៀបចំបង្កើតនិងអនុវត្តជាបណ្តើរៗ។ វឌ្ឍនភាពសំខាន់ៗរួមមានដូចខាងក្រោម ៖

- រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបានពង្រឹងដើម្បីអនុវត្តតួនាទីក្នុងការគ្រប់គ្រង សម្របសម្រួលកម្មវិធី និងការរៀបចំតាក់តែងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនានា។ ជាក់ស្តែងឯកសារគោលនយោបាយ ច្បាប់ គោលការណ៍ណែនាំ ឯកសារបណ្តុះបណ្តាលជាច្រើនត្រូវបាន និងកំពុងអភិវឌ្ឍ សម្រាប់ពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី និងបុគ្គលិកនៅថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។ សមត្ថភាព និងការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការកំពុងមានការកើនឡើងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ក្នុងក្របខ័ណ្ឌនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ការរៀបចំរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើសមាហរណកម្មមន្ត្រី និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងរចនាសម្ព័ន្ធថ្មីនេះបានសម្រេចក្នុងរយៈពេលមួយដ៏ខ្លី។ ជាមួយគ្នានេះដែរ ប្រព័ន្ធកសាងផែនការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឲ្យអនុវត្ត និងកែលំអជាបណ្តើរៗ។ ដោយឡែក រដ្ឋបាលក្រុង ស្រុក ត្រូវបាននិងកំពុងរៀបចំឲ្យក្លាយទៅថ្នាក់រដ្ឋបាលដែលមានតួនាទីជាសំខាន់មួយក្នុងនាមជារដ្ឋបាលមូលដ្ឋាន ដែលនឹងត្រូវបានពង្រឹងនូវស្វ័យភាពជាបណ្តើរៗ ក្នុងការគ្រប់គ្រងចាត់ចែងធនធាននានាសម្រាប់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនានា។
- អនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការចាត់ចែងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្ត។ ក្រៅពីនេះ សេចក្តីព្រាងគោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិកំពុងត្រូវបានរៀបចំ និងរំពឹងថាត្រូវបានអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។
- ពាក់ព័ន្ធនឹងការផ្ទេរមុខងារ ក្រសួងចំនួន៥បានរៀបចំបញ្ចប់របាយការណ៍ស្តីពីការវិភាគមុខងារ និងបានចាប់ផ្តើមរៀបចំកិច្ចដំណើរការពិនិត្យឡើងវិញនូវមុខងារនានា ដើម្បីជាមូល

ដ្ឋានក្នុងការរៀបចំនូវបញ្ជីបេក្ខភាពនៃមុខងារ និងការកំណត់អំពីថ្នាក់រដ្ឋបាលសមស្រប សម្រាប់ការផ្ទេរនូវមុខងារទាំងនេះ។

- ការអនុម័តច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្កើតមូលនិធិក្រុង ស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក និងការចាប់ផ្តើម វិភាជន៍មូលនិធិក្រុង ស្រុកទៅឲ្យក្រុង ស្រុកនីមួយៗ ព្រមទាំងការបន្តនិរន្តរភាពនៃការអនុវត្ត ប្រព័ន្ធមូលនិធិឃុំ សង្កាត់ប្រកបដោយភាពរលូនបានបង្ហាញឲ្យឃើញនូវជោគជ័យគួរឲ្យកត់ សម្គាល់មួយនៃការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ។
- សមិទ្ធផលសំខាន់ៗខាងលើពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស កិច្ចដំណើរ ការផ្ទេរមុខងារ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បានក្លាយជា មូលដ្ឋានគ្រឹះ និងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជាបណ្តើរៗនូវសមត្ថភាពផ្នែក ប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេលដ៏ខ្លីនៃការអនុវត្តផអ៣។ លើសពីនេះ ការអនុម័ត និងការដាក់ឲ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យ ភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សេចក្តីណែនាំបច្ចេកទេស ស្តីពីវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ជាសាធារណៈ និងស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាការឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការពង្រឹងក្របខ័ណ្ឌ គណនេយ្យភាពបែបប្រជាធិបតេយ្យ និងសង្គមនៅមូលដ្ឋាន។
- សមិទ្ធផលដ៏សំខាន់មួយផ្សេងទៀត ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធព័ត៌មាន និងទិន្នន័យស្តីពី អភិបាលកិច្ច និងកិច្ចអភិវឌ្ឍនៅមូលដ្ឋាន។ ក្នុងអំឡុងពេលនៃការអនុវត្តអជ៣ ប្រព័ន្ធ ព័ត៌មាន និងទិន្នន័យជាច្រើនត្រូវបានអភិវឌ្ឍ និងដាក់ឲ្យប្រើប្រាស់។ ជាមួយគ្នានេះដែរ ថ្មីៗ នេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានបង្កើតនូវប្រព័ន្ធទិន្នន័យជាតិស្តីពីផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដើម្បីធានាដល់ការតាមដាន ការត្រួតពិនិត្យ និងការអនុវត្តឲ្យកាន់តែ មានភាពប្រសើរឡើង។ ប្រព័ន្ធព័ត៌មាន និងទិន្នន័យនេះ កំពុងត្រូវបានយកទៅប្រើប្រាស់ សម្រាប់ការសិក្សាស្រាវជ្រាវ និងការរៀបចំរបាយការណ៍របស់ក្រសួង ស្ថាប័ន និង អ្នកពាក់ព័ន្ធជាច្រើន។

### ២.២. បញ្ហាប្រឈម

ជាមួយគ្នានឹងការសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនដូចបានគូសបញ្ជាក់ខាងលើ ការ អនុវត្តផអ៣ក្នុងអំឡុងឆ្នាំ២០១១ដល់២០១៣ ក៏បានជួបប្រទះបញ្ហាប្រឈមជាច្រើនផងដែរ។ ក្រៅពី ការចាប់ផ្តើមយឺតរយៈពេល៦ខែ និងការកាត់បន្ថយនូវការគាំទ្រផ្នែកហិរញ្ញវត្ថុដែលបានរំពឹងទុកសម្រាប់ កិច្ចដំណើរការកំណែទម្រង់ ការអនុវត្តផអ៣ក៏បានជួបប្រទះនូវបញ្ហាប្រឈមចម្បងៗមួយចំនួនផ្សេង ទៀតផងដែរ។ បញ្ហាប្រឈមជាចម្បងៗទាំងនោះរួមមាន ៖

ក). **អំពីការអភិវឌ្ឍគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត** ដើម្បីគាំទ្រ និងផ្តល់លទ្ធភាពក្នុង

ការពង្រឹងការទទួលខុសត្រូវ និងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ភាពយឺតយ៉ាវ និងការខ្វះចន្លោះនៃការអភិវឌ្ឍគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន បានបង្កឲ្យមានការវិវត្តតិចតួចពាក់ព័ន្ធនឹងការផ្ទេរការសិទ្ធិគ្រប់គ្រងមន្ត្រី បុគ្គលិកទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការយឺតយ៉ាវក្នុងការរៀបចំឲ្យមានយន្តការជាក់លាក់ផ្សេងៗពាក់ព័ន្ធទៅនឹងការបង្កើនប្រភពចំណូល បន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) ដូចជា ការរៀបចំយន្តការផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) យន្តការផ្តល់ហិរញ្ញប្បទានមានភ្ជាប់ល័ក្ខខ័ណ្ឌ និងប្រភពចំណូលផ្ទាល់ជាដើម ព្រមទាំងបង្កឲ្យមានការអូសបន្លាយក្នុងការផ្ទេរមុខងារជាក់លាក់មួយចំនួនឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ខ). **អំពីការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ** ឲ្យក្លាយជាស្ថាប័នដែលមានសមត្ថភាពទាំងផ្នែកស្ថាប័ន និងផ្នែកបុគ្គល ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរឆ្ពោះទៅកាន់ប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ភាពយឺតយ៉ាវរបស់ក្រសួង ស្ថាប័នក្នុងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីកិច្ចប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស និងការអនុវត្តមុខងារបានបង្កឲ្យមានការផ្លាស់ប្តូរដ៏តិចតួចនូវសមត្ថភាពផ្នែកអភិវឌ្ឍន៍គោលនយោបាយមូលដ្ឋាន និងសមត្ថភាពផ្នែកការងារសង្គមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងអណត្តិទីមួយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

គ). **អំពីការអភិវឌ្ឍក្របខ័ណ្ឌ និងប្រព័ន្ធត្រួតពិនិត្យ** ដែលត្រូវអនុវត្តដោយថ្នាក់ជាតិ ដើម្បីកែលំអ និងពង្រឹងប្រព័ន្ធត្រួតពិនិត្យបច្ចុប្បន្ន ក្នុងគោលបំណងធានាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តនូវស្វ័យភាពរបស់ខ្លួន ព្រមទាំងមានគណនេយ្យភាពនូវរាល់សកម្មភាពរបស់ខ្លួន។ ជាទូទៅ ការអភិវឌ្ឍក្របខ័ណ្ឌ និងប្រព័ន្ធត្រួតពិនិត្យនេះនៅពុំទាន់មានការវិវត្ត ដូចការរំពឹងទុកនៅក្នុងផអ៣ឡើយ។ ជាក់ស្តែង ការរៀបចំសម្រាប់ការធ្វើអធិការកិច្ចជាប្រចាំលើរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលជាផ្នែកមួយនៃយន្តការត្រួតពិនិត្យនីត្យានុកូលភាព ព្រមទាំងការរៀបចំយន្តការនានាសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការត្រួតពិនិត្យការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការរៀបចំនូវយន្តការដោះស្រាយទំនាស់នៅមូលដ្ឋាននៅមិនទាន់ត្រូវបានរៀបចំឲ្យមានលក្ខណៈជាប្រព័ន្ធនៅឡើយ។

ដោយផ្អែកលើបញ្ហាប្រឈមជាចម្បងៗខាងលើ ស្ថាប័នអនុវត្តផអ៣ទាំងអស់បានពិភាក្សាយ៉ាងស៊ីជម្រៅអំពីឫសគល់នៃបញ្ហា ដើម្បីឈានទៅកំណត់បាននូវដំណោះស្រាយនានា និងបានធ្វើការវាយតម្លៃអំពីសមត្ថភាព និងលទ្ធភាពរបស់ស្ថាប័ននីមួយៗ ព្រមទាំងបានកំណត់អំពីសកម្មភាពជាអាទិភាពនានាសម្រាប់ឆ្នាំ២០១៤ ដើម្បីធ្វើឲ្យសម្រេចនូវលទ្ធផលរំពឹងទុកសំខាន់ៗរបស់ផអ៣ដែលមិនទាន់បានសម្រេចនាពេលកន្លងមក។ អាទិភាពទាំងនោះត្រូវបានបរិយាយក្នុងផ្នែកទី៣ខាងក្រោម។

# ផ្នែកទី៣

# ក្របខ័ណ្ឌនៃកម្មវិធី និងលទ្ធផលរំពឹងទុកជាអាទិភាព

## ៣.១. ក្របខ័ណ្ឌនៃកម្មវិធី

ដោយផ្អែកជាសំខាន់ទៅលើគោលបំណង និងគោលដៅរបស់ផអ៣ លទ្ធផលរំពឹងទុករបស់អនុកម្មវិធីនានានៃផអ៣សម្រាប់ឆ្នាំ២០១៤ នៅតែត្រូវបានបន្តរៀបចំទៅតាមអនុកម្មវិធីចំនួន៦ ដែលត្រូវអនុវត្តដោយក្រសួង ស្ថាប័នសំខាន់ៗមួយចំនួន។ ការរៀបចំបែបនេះមានគោលបំណងធ្វើឲ្យសម្រេចនូវលទ្ធផលរំពឹងទុករបស់ផអ៣ដែលមិនទាន់បានសម្រេចនាពេលកន្លងមក ក្នុងន័យឆ្លើយតបទៅនឹងចំណុចស្នូលនៃផអ៣។ តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងដើម្បីរៀបចំឯកសារនេះឲ្យមានលក្ខណៈជាយុទ្ធសាស្ត្រ ព្រមទាំងមានលទ្ធផលរំពឹងទុកច្បាស់លាស់ អាស្រ័យហេតុនេះ អាទិភាពសំខាន់ៗនានាសម្រាប់ឆ្នាំ២០១៤ត្រូវបានកំណត់យ៉ាងជាក់លាក់ សំដៅធានាដល់ការរៀបចំ និងការអនុវត្តកម្មវិធីមួយដែលអាចមានលទ្ធភាពងាយស្រួលក្នុងការគ្រប់គ្រង និងតាមដានត្រួតពិនិត្យនូវលទ្ធផលរំពឹងទុកទាំងនោះ។ បន្ទាប់ពីឯកសារពន្យារពេលផអ៣នេះត្រូវបានអនុម័ត ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤នឹងត្រូវរៀបចំឡើងយ៉ាងលម្អិតដោយកំណត់អំពីសកម្មភាព ថវិកា អង្គភាពទទួលខុសត្រូវ និងពេលវេលាជាក់លាក់ដើម្បីសម្រេចបាននូវអាទិភាពទាំងនោះ ព្រមទាំងលទ្ធផលរំពឹងទុកសំខាន់ៗដទៃទៀតដែលពុំបានបរិយាយនៅផ្នែកខាងក្រោមនេះ។

## ៣.២. លទ្ធផលរំពឹងទុកជាអាទិភាពនានាសម្រាប់ឆ្នាំ២០១៤

### ៣.២.១. ការពង្រឹងការគ្រប់គ្រងកម្មវិធី

ដើម្បីពង្រឹងការគ្រប់គ្រងលើការអនុវត្តកម្មវិធី ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការពិនិត្យឡើងវិញនូវតួនាទីរបស់ គ.ជ.អ.ប ក្នុងការគ្រប់គ្រងការអនុវត្តកម្មវិធី ការសម្របសម្រួលឲ្យមានការឯកភាពលើគោលនយោបាយនានាដែលមានលក្ខណៈជាយុទ្ធសាស្ត្រពីរាជរដ្ឋាភិបាល ការពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់អនុគណៈកម្មាធិការនានានៃគ.ជ.អ.ប និងការធានាលើការអនុវត្តតាមសេចក្តីសម្រេចនានារបស់គ.ជ.អ.ប ដែលកិច្ចការទាំងអស់នេះត្រូវខិតខំបញ្ចប់ឲ្យបាននៅក្នុងត្រីមាសទី១នៃឆ្នាំ២០១៤។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធានាថា កិច្ចប្រជុំប្រចាំត្រីមាសជាមួយស្ថាប័នអនុវត្តផអ៣ត្រូវធ្វើឡើងយ៉ាងទៀងទាត់នៅក្នុងឆ្នាំ២០១៤ ដោយមានរបៀបវារៈ និងការឯកភាពគ្នា ព្រមទាំងមានផែនការសកម្មភាពដែលមានចំណុចដៅ និងក្របខ័ណ្ឌពេលវេលាជាក់លាក់សម្រាប់អនុវត្តនូវកិច្ចការដែលបានឯកភាពគ្នាទាំងនោះ។

### ៣.២. ២. មូលនិធិក្រុង ស្រុក

ក្នុងឆ្នាំ២០១៤ មូលនិធិក្រុង ស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកនឹងត្រូវបានអនុវត្តយ៉ាងពេញលេញ។ គម្រោងអភិវឌ្ឍក្រុង ស្រុកនឹងត្រូវបានធ្វើលទ្ធកម្មដោយប្រើប្រាស់សេចក្តីណែនាំស្តីពីនីតិវិធីលទ្ធកម្មក្រុង ស្រុក ព្រមទាំងការបណ្តុះបណ្តាលលើការគ្រប់គ្រងហិរញ្ញវត្ថុនឹងត្រូវផ្តល់ទៅឲ្យរដ្ឋបាលក្រុង ស្រុកទាំងអស់នៅត្រឹមដំណាច់ត្រីមាសទី២។ លើសពីនេះ ប្រព័ន្ធ និងនីតិវិធីទាំងនោះនឹង

ត្រូវបានពិនិត្យឡើងវិញ ព្រមទាំងវាយតម្លៃនៅក្នុងត្រីមាសទី៣ ហើយការកែសម្រួលប្រព័ន្ធ និងនីតិវិធីទាំងនោះត្រូវរៀបចំឲ្យបានចប់សព្វគ្រប់ និងធ្វើការណែនាំដល់រដ្ឋបាលក្រុង ស្រុកនៅត្រឹមដំណាច់ឆ្នាំ២០១៤។ ដោយឡែក ធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិក្រុង ស្រុកយ៉ាងតិចចំនួនប្រមាណ៨០% នឹងត្រូវបានប្រើប្រាស់ដោយរដ្ឋបាលក្រុង ស្រុក នៅដំណាច់ខែធ្នូ ឆ្នាំ២០១៤។

**៣.២.៣. ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ផ្អែកលើការសិក្សានៅឆ្នាំ២០១៣ស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានរៀបចំបញ្ចប់ និងអនុម័តនៅដំណាច់ត្រីមាសទី២នៃឆ្នាំ២០១៤។ បន្ទាប់មក ត្រូវរៀបចំ និងអនុវត្តសាកល្បងលើការប្រមូល និងការគ្រប់គ្រងចំណូលផ្ទាល់នៅក្រុង ស្រុក ខណ្ឌមួយចំនួននៅត្រីមាសបន្ទាប់ ហើយត្រូវធ្វើការវាយតម្លៃលើការអនុវត្តសាកល្បងនេះនៅដំណាច់ឆ្នាំ២០១៤ ដើម្បីឈានទៅការពង្រីកការអនុវត្តនៅឆ្នាំ២០១៥។

**៣.២.៤. ការផ្ទេរមុខងារ**

លិខិតបទដ្ឋានគតិយុត្តស្តីពីមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានរៀបចំ និងអនុម័ត ព្រមទាំងត្រូវបានផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់យ៉ាងយូរនៅត្រីមាសទី២នៃឆ្នាំ២០១៤។ ក្នុងពេលជាមួយគ្នានេះដែរ ការសាកល្បងលើការផ្ទេរមុខងារក្នុងវិស័យអាទិភាពយ៉ាងតិចចំនួនពីរ (វិស័យសុខាភិបាល និងអនាម័យនៅជនបទ) នឹងត្រូវបានរៀបចំ និងអនុវត្តនៅឆ្នាំ២០១៤ ព្រមទាំងត្រូវបានធ្វើការវាយតម្លៃលើការអនុវត្តសាកល្បងនៃការផ្ទេរមុខងារទាំងនេះនៅត្រីមាសទី៣នៃឆ្នាំ២០១៤ ដើម្បីធានាដល់ការធ្វើសេចក្តីសម្រេចចិត្តស្តីពីផែនការអនុវត្តបន្តនៅក្នុងឆ្នាំ២០១៥។

**៣.២.៥. ក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម**

ការអនុវត្តសាកល្បងអំពីឧបករណ៍នានាសម្រាប់ការអនុវត្តផែនការអនុវត្តផែនការយុទ្ធសាស្រ្តស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងត្រូវអនុវត្តបញ្ចប់នៅត្រីមាសទី១នៃឆ្នាំ២០១៤។ ដោយឡែក សេចក្តីណែនាំ និងផែនការអនុវត្តយុទ្ធសាស្រ្តនេះនឹងត្រូវបានរៀបចំបញ្ចប់នៅត្រីមាសទី២នៃឆ្នាំ២០១៤។ ការបិទផ្សាយព័ត៌មានជាសាធារណៈ ការតាមដានរបស់ប្រជាពលរដ្ឋ និងការរៀបចំនូវផែនការសកម្មភាពក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គមនឹងត្រូវបានអនុវត្តនៅគ្រប់ឃុំទាំងអស់ក្នុងស្រុកយ៉ាងតិចចំនួន២០នៅដំណាច់ឆ្នាំ២០១៤។

**៣.២.៦. លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានរៀបចំបញ្ចប់ និងអនុម័តនៅត្រីមាសទី១នៃឆ្នាំ២០១៤។ នៅត្រីមាសទី២នៃឆ្នាំ២០១៤ យន្តការគាំទ្រសម្រាប់ការអនុវត្តលក្ខន្តិកៈនេះនឹងត្រូវបានរៀបចំឡើង ដោយរួមបញ្ចូលទាំងការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងការអភិវឌ្ឍប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង ដើម្បីធានាដល់ការពង្រីកការអនុវត្តលក្ខន្តិកៈនេះក្នុងត្រីមាសបន្តបន្ទាប់ទៀតនៃឆ្នាំ២០១៤។

### ៣.២. ៧. ការពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ការពិនិត្យឡើងវិញអំពីកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីវិធីសាស្ត្រនៃការផ្តល់សេវាប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការណែនាំអំពីសេចក្តីព្រាងនៃវិធានផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកនឹងត្រូវអនុវត្តនៅក្នុងឆមាសទី១នៃឆ្នាំ២០១៤។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រស្តីពីការពង្រឹងតួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានរៀបចំ និងអនុម័តនៅចុងឆមាសទី១នៃឆ្នាំ២០១៤ ដើម្បីធានាដល់ការអនុវត្តយុទ្ធសាស្ត្រនេះសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី២។

### ៣.២.៨. ការរៀបចំប្រព័ន្ធកសាងផែនការ និងថវិកាសម្រាប់ប្រភេទផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

សេចក្តីព្រាងគោលនយោបាយស្តីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានរៀបចំ និងអនុម័តនៅក្នុងត្រីមាសទី១នៃឆ្នាំ២០១៤។ ក្នុងអំឡុងពេលត្រីមាសទី២ ចាំបាច់ត្រូវរៀបចំឲ្យមានការសិក្សាមួយ ដើម្បីធានាឲ្យមានភាពប្រទាក់ក្រឡាគ្នាយ៉ាងល្អប្រសើររវាងកិច្ចដំណើរការនៃការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលការសិក្សានេះផ្តោតទៅលើការពិនិត្យមើលឡើងវិញនូវសេចក្តីណែនាំនានាដែលមាននាពេលបច្ចុប្បន្នពាក់ព័ន្ធនឹងការកសាងផែនការ និងការរៀបចំថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការកែសម្រួលសេចក្តីណែនាំទាំងនោះសម្រាប់ប្រភេទផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការបណ្តុះបណ្តាលអំពីសេចក្តីណែនាំដែលបានកែសម្រួលទាំងនេះនឹងត្រូវអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០១៤។

### ៣.២.៩.ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច

លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ចមួយនឹងត្រូវបានរៀបចំឡើងនៅដំណាច់ត្រីមាសទី២នៃឆ្នាំ២០១៤។ នៅក្នុងត្រីមាសទី៣ ប្រព័ន្ធនេះនឹងត្រូវបានអនុវត្តក្នុងលក្ខណៈសាកល្បងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ព្រមទាំងត្រូវបានវាយតម្លៃ ហើយបន្ទាប់មក ផែនការលម្អិតមួយសម្រាប់ការអនុវត្តប្រព័ន្ធនេះនៅក្នុងឆ្នាំ២០១៥ នឹងត្រូវបានរៀបចំនៅក្នុងត្រីមាសទី៤នៃឆ្នាំ២០១៤។

### ៣.២.១០. ការពង្រឹងសមត្ថភាពផ្នែករដ្ឋបាលរបស់ក្រុង ស្រុក

ថវិកាកម្មវិធីនឹងត្រូវបានផ្តល់ឲ្យទៅរដ្ឋបាលក្រុង ស្រុក ចាប់ផ្តើមពីត្រីមាសទី១នៃឆ្នាំ២០១៤ ដើម្បីគាំទ្រដល់ការជ្រើសរើសមន្ត្រីកិច្ចសន្យា និងការអនុវត្តសកម្មភាពជាក់លាក់នានាដែលពុំអាចរ៉ាប់រងដោយមូលនិធិក្រុង ស្រុក។ សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការរបស់រដ្ឋបាលក្រុង ស្រុកនឹងត្រូវបានរៀបចំបញ្ចប់នៅដើមត្រីមាសទី២ ព្រមទាំងត្រូវបានផ្សព្វផ្សាយតាមរយៈការរៀបចំកម្មវិធីបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុកទាំងអស់។ ក្រៅពីនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានពិនិត្យមើល និងកែសម្រួលឡើងវិញនៅពាក់កណ្តាលឆ្នាំ២០១៤ដែលជាផ្នែកមួយនៃកិច្ចដំណើរការរៀបចំតាក់តែងផអ៣ជំហានបន្ទាប់នៃកម្មវិធីជាតិ។

### ៣.២.១១. សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងឆ្នាំ២០១៣ សមាគមក្រុមប្រឹក្សារាជធានី ខេត្តត្រូវបានបង្កើតរួចហើយ។ ដោយឡែកសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៅតាមរាជធានី ខេត្តចំនួន១១ ក៏ត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១៣ផងដែរ។ អាស្រ័យហេតុនេះ នៅត្រីមាសទី១នៃឆ្នាំ២០១៤ សមាគមទាំង១១នេះចាំបាច់ត្រូវចងក្រងដើម្បីបង្កើតឲ្យទៅជាសម្ព័ន្ធភាពជាតិនៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ បន្ទាប់មក សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៅតាមខេត្តចំនួន១៣ផ្សេងទៀតនឹងត្រូវបានបង្កើតឡើងជាបន្តបន្ទាប់នឹងត្រូវបានបញ្ចូលទៅក្នុងសម្ព័ន្ធភាពជាតិខាងលើនេះផងដែរ។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋានសម្រាប់គាំទ្រសមាគមទាំងពីរនឹងត្រូវបានរៀបចំឡើងវិញ ដោយមានការកំណត់អំពីល័ក្ខខ័ណ្ឌការងារយ៉ាងជាក់លាក់។

### ៣.២.១២. យេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មយេនឌ័រ ផែនការការងារមួយស្ដីពីបញ្ហានានាពាក់ព័ន្ធនឹងយេនឌ័រសម្រាប់ឆ្នាំ២០១៤នឹងត្រូវបានរៀបចំឡើងដោយមានការកំណត់អំពីសកម្មភាពជាក់លាក់នានាដែលត្រូវអនុវត្តដោយស្ថាប័នអនុវត្តផអ៣នីមួយៗ។ លទ្ធផលនៃការធ្វើសវនកម្មយេនឌ័រក៏នឹងត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ និងសម្រាប់ការកែសម្រួលយុទ្ធសាស្ត្រស្ដីពីការបញ្ជ្រាបយេនឌ័រផងដែរ។

### ៣.២.១៣. ការរៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិ

ល័ក្ខខ័ណ្ឌការងារសម្រាប់ការរៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិនឹងត្រូវបានរៀបចំ និងមានការឯកភាពជាមួយដៃគូអភិវឌ្ឍន៍នានានៅក្នុងខែមករា ឆ្នាំ២០១៤។ ការរៀបចំសេចក្ដីព្រាងលើកទី១នៃផអ៣ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិនឹងត្រូវបញ្ចប់ឱ្យបានក្នុងខែឧសភា ឆ្នាំ២០១៤។ បន្ទាប់មក សេចក្ដីព្រាងផែនការនេះនឹងត្រូវរៀបចំឲ្យមានការសិក្សាវាយតម្លៃរួមគ្នានៅក្នុងខែកក្កដា ឆ្នាំ២០១៤ ហើយនឹងត្រូវបានអនុម័តយ៉ាងយូរនៅក្នុងខែកញ្ញា ឆ្នាំ២០១៤។

## ផ្នែកទី៤

## ការគ្រប់គ្រងកម្មវិធី

ការខិតខំលើកកម្ពស់តួនាទី ការទទួលខុសត្រូវ និងកិច្ចដំណើរការរបស់អនុគណៈកម្មការទាំង៤របស់ គ.ជ.អ.ប ព្រមទាំងតួនាទីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងនាមជាសេនាធិការឲ្យ គ.ជ.អ.ប និងអនុគណៈកម្មាធិការទាំង៤ គឺជាកិច្ចការអាទិភាពដែលត្រូវបន្តអនុវត្តសម្រាប់ឆ្នាំ២០១៤នេះ ដើម្បីធានាដល់ការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការគាំទ្រដល់ការអនុវត្តផែនការសកម្មភាពនៃការពន្យារពេលផអ៣ ក៏ដូចជាការរៀបចំ និងការអនុវត្តផអ៣ដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់ដ៏សំខាន់មួយក្នុងចំណោមកំណែទម្រង់ធំៗទាំង៣របស់រាជរដ្ឋាភិបាល អាស្រ័យហេតុនេះ ចាំបាច់ត្រូវមានការចូលរួមអនុវត្តយ៉ាងសកម្មពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ ក្នុងន័យនេះ ការពង្រឹងនូវភាពជាម្ចាស់របស់ក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីនានារបស់ផអ៣ តាមរយៈការបង្កើននូវការទទួលខុសត្រូវជាបណ្តើរៗទាំងផ្នែកថវិកា និងផ្នែកជំនាញរបស់ស្ថាប័ននីមួយៗលើការអនុវត្តសកម្មភាពជាអាទិភាពនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺនៅតែជាកត្តាគន្លឹះ ដើម្បីធានាដល់ការចូលរួមចំណែកក្នុងការសម្របសម្រួល និងការគាំទ្រជាទូទៅដល់ការអនុវត្តកម្មវិធី។

### ៤.១. ថិរវេលា

ពេលវេលាសម្រាប់អនុវត្តផអ៣ដែលបានពន្យារពេលនេះ គឺចាប់ផ្តើមពីថ្ងៃ០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីបន្តសម្រេចឲ្យបាននូវចំណុចដៅសំខាន់ៗជាមូលដ្ឋានគ្រឹះនៃកំណែទម្រង់ ដែលបានកំណត់ក្នុងផអ៣។

### ៤.២. ការសម្របសម្រួល ការគ្រប់គ្រង និងការអនុវត្តកម្មវិធី

ការសម្របសម្រួល និងការគ្រប់គ្រងលើការអនុវត្តកម្មវិធីនៃការពន្យារពេលផអ៣នេះ គឺនៅតែស្ថិតក្រោមការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងនាមជាសេនាធិការរបស់ គ.ជ.អ.ប ព្រមទាំងត្រូវបានបែងចែកជាអនុកម្មវិធីនានា ដែលត្រូវទទួលខុសត្រូវអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងកិច្ចការនារី សមាគមរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយឡែក ភាពជាដៃគូជាមួយបណ្តាក្រសួងវិស័យផ្សេងៗទៀត នឹងត្រូវបានពង្រឹងបន្ថែមទៀតតាមរយៈការរៀបចំ និងអនុវត្តសាកល្បងនូវការផ្ទេរមុខងារ។

### ៤.៣. ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីនានា

ក្នុងរយៈពេលកន្លងមក ក្រសួង ស្ថាប័នអនុវត្តនានាបានរៀបចំបង្កើតឡើងនូវក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីនីមួយៗក្នុងស្ថាប័នសាមី ដើម្បីទទួលខុសត្រូវអនុវត្តអនុកម្មវិធីនីមួយៗរបស់ផអ៣។

យ៉ាងណាមិញ ដើម្បីធានាដល់ការពង្រឹងនូវការចូលរួមក្នុងអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយភាពជាម្ចាស់របស់គ្រប់ក្រសួង ស្ថាប័ននានាជាពិសេសស្ថាប័នអនុវត្តអនុកម្មវិធីនានានៃផអ៣ តម្រូវឲ្យមានការពិនិត្យមើលឡើងវិញ និងការពង្រឹងនូវបែបផែននៃការគ្រប់គ្រង និងការអនុវត្តអនុកម្មវិធីនានាបច្ចុប្បន្ន ដើម្បីធានាថា ផែនការសកម្មភាពដែលពាក់ព័ន្ធនឹងអនុកម្មវិធី ត្រូវបានបញ្ជ្រាបជាបណ្តើរៗទៅក្នុងផែនការសកម្មភាពនានាដែលគាំទ្រដោយថវិការបស់ក្រសួង ស្ថាប័នសាមី។ ក្នុងន័យនេះ សកម្មភាពជាអាទិភាពនានារបស់អនុកម្មវិធីនីមួយៗសម្រាប់ឆ្នាំ២០១៤នឹងត្រូវបានរៀបចំឲ្យមានការទទួលខុសត្រូវក្នុងក្របខ័ណ្ឌជាការគ្រប់គ្រង និងការអនុវត្តដោយអង្គភាពពាក់ព័ន្ធជាក់លាក់របស់ក្រសួង ស្ថាប័ន។

### ៤.៤. ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងរយៈពេលកន្លងមក បន្ទាប់ពីការរំសាយគណៈកម្មាធិការប្រតិបត្តិរាជធានី ខេត្ត យន្តការក្រុមការងារផអ៣របស់រាជធានី ខេត្ត ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបការអនុវត្តកម្មវិធីផអ៣ទៅក្នុងស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដើម្បីធានាបាននូវការបន្តយន្តការគាំទ្របច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ទោះបីយ៉ាងនេះក្តី យន្តការនេះត្រូវបានពិនិត្យឃើញថា នៅពុំទាន់ត្រូវបានរៀបចំជាបែបផែន និងមានកិច្ចដំណើរការដែលអាចធានាដល់ការសម្រេចបាននូវគោលបំណងខាងលើនេះនៅឡើយ។ អាស្រ័យហេតុនេះ ដើម្បីធានាបាននូវការអនុវត្តកម្មវិធីផអ៣នៅរដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចការជាអាទិភាពសម្រាប់ឆ្នាំ២០១៤មានដូចខាងក្រោម ៖

- ពិនិត្យ និងកែសម្រួលឡើងវិញនូវយន្តការក្រុមការងារផអ៣របស់រាជធានី ខេត្ត ដើម្បីធានាដល់ការលើកកម្ពស់នូវភាពជាម្ចាស់ ការទទួលខុសត្រូវ និងសមត្ថភាពរបស់ទីចាត់ការ និងអង្គភាពនានារបស់សាលារាជធានី ខេត្តក្នុងការគ្រប់គ្រង និងការអនុវត្តសកម្មភាពជាក់លាក់នានារបស់កម្មវិធីផអ៣។
- បន្តពង្រឹងសមត្ថភាពរបស់ក្រុង ស្រុក តាមរយៈការផ្តល់នូវមន្ត្រីកិច្ចសន្យា និងការផ្តល់ថវិកាកម្មវិធីដើម្បីគាំទ្រដល់ក្រុង ស្រុកក្នុងការអនុវត្តសកម្មភាពជាអាទិភាពនានាដែលមិនអាចរ៉ាប់រងដោយមូលនិធិក្រុង ស្រុក។
- ពិនិត្យនិងរៀបចំឡើងវិញនូវការដាក់ពង្រាយបុគ្គលិកនៅតាមទីចាត់ការ និងអង្គភាពនានាដើម្បីលើកកំពស់នូវតួនាទី និងការទទួលខុសត្រូវសម្រាប់អនុវត្តកម្មវិធី។
- ធ្វើការវិភាគអំពីខ្ទង់ថវិកា និងតម្រូវការជាក់លាក់នានាដើម្បីគាំទ្រដល់ការដាក់បញ្ចូលជាបណ្តើរៗនូវការរ៉ាប់រងចំណាយសម្រាប់សកម្មភាពនានានៃកម្មវិធីផអ៣ ទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

### ៤.៥. ការគ្រប់គ្រង និងការតាមដានការអនុវត្តកម្មវិធី

#### ៤.៥.១. ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤

ដើម្បីធានាបាននូវការអនុវត្តផអ៣ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ ចាំបាច់ត្រូវបាន

រៀបចំឡើងដោយមានការចូលរួម និងប្រឹក្សាយោបល់ពីអ្នកពាក់ព័ន្ធនានា ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកំណត់នូវសកម្មភាពជាអាទិភាពនានាដែលត្រូវសម្រេចឲ្យបាននូវលទ្ធផលរំពឹងទុកនានាដែលបានកំណត់នៅក្នុងឯកសារពន្យារពេលផអ៣នេះ។ ជាមួយគ្នានេះដែរ ការរៀបចំផែនការសកម្មភាពនិងថវិកាឆ្នាំ២០១៤ត្រូវកំណត់ឲ្យបានច្បាស់លាស់នូវអង្គភាពទទួលខុសត្រូវនៃស្ថាប័នអនុវត្តនីមួយៗក្នុងការអនុវត្តសកម្មភាពជាក់លាក់នានាដែលពាក់ព័ន្ធនឹងតួនាទី ភារកិច្ចរបស់អង្គភាពនោះ។ បន្ថែមលើនេះទៀត ផែនការសកម្មភាពនិងថវិកាឆ្នាំ២០១៤ ក៏ចាំបាច់ត្រូវឆ្លុះបញ្ចាំងអំពីការគាំទ្រដ៏ជាក់លាក់ដល់កិច្ចប្រតិបត្តិការរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌផងដែរ ដើម្បីធានាឲ្យមានការរៀបចំនូវសេចក្តីសម្រេចរួមយ៉ាងច្បាស់លាស់រវាងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។

**៤.៥.២. ប្រព័ន្ធទិន្នន័យព័ត៌មានសម្រាប់ការគ្រប់គ្រងកម្មវិធី**

ក្នុងរយៈពេលកន្លង ប្រព័ន្ធទិន្នន័យគ្រប់គ្រងផែនការសកម្មភាពនិងថវិកា(NAD) និងប្រព័ន្ធទិន្នន័យព័ត៌មានសម្រាប់ការគ្រប់គ្រង(MIS)ត្រូវបានរៀបចំ និងដាក់ឲ្យដំណើរការជាបណ្តើរៗ ដើម្បីធានាដល់ការតាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាព និងថវិកា ព្រមទាំងបញ្ហាប្រឈម និងការរៀបចំនូវរបាយការណ៍នានា។ ក្នុងឆ្នាំ២០១៤ កិច្ចការជាអាទិភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់ គឺការកែលំអប្រព័ន្ធទិន្នន័យគ្រប់គ្រងផែនការសកម្មភាពនិងថវិកា ដើម្បីធានានូវការឆ្លុះបញ្ចាំងឲ្យបានច្បាស់លាស់អំពីសូចនាករក្នុងកម្រិតលទ្ធផលរំពឹងទុក និងថវិកា ព្រមទាំងទំនាក់ទំនងរវាងសូចនាករ និងថវិកា និងមានលទ្ធភាពគ្រប់ដណ្តប់ទាំងទិន្នន័យ និងព័ត៌មាននានារបស់គម្រោង និងកម្មវិធីដាច់ដោយឡែកនានាផងដែរ។

## ៤.៦. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

ជារួម ការរៀបចំគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីធានាជាបណ្តើរៗនូវភាពជាម្ចាស់របស់មន្ត្រីរាជការក្នុងអនុវត្តកម្មវិធីនៃផអ៣បានបង្ហាញឲ្យឃើញថាទោះបីជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់មួយចំនួនក៏ដោយ ក៏កិច្ចការនេះនៅតែជាបញ្ហាប្រឈមគួរឲ្យព្រួយបារម្ភនៅឡើយបើប្រៀបធៀបទៅនឹងចំណុចដៅនៃផអ៣។ យោងតាមការសិក្សាវាយតម្លៃអំពីស្ថានភាពនៃការគ្រប់គ្រងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០១២ បានបង្ហាញឲ្យឃើញថា ប្រព័ន្ធគ្រប់គ្រងការងារបុគ្គលិក ព្រមទាំងបរិមាណនិងសមត្ថភាពរបស់មន្ត្រីនៅតាមអង្គភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ក្រុង ស្រុកនៅតែមានភាពខ្វះខាតនៅឡើយ។ អាស្រ័យហេតុនេះ កិច្ចការជាអាទិភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់ជាចម្បងក្នុងឆ្នាំ២០១៤ រួមមាន ៖

- ពង្រឹងសមត្ថភាពមន្ត្រីដឹកនាំរបស់អង្គភាពទាំងបួននៃលេខាធិការដ្ឋាន គ.ជ.អ.ប និងជ្រើសរើសមន្ត្រីសម្រាប់បំពេញបន្ថែមនូវមុខដំណែងនានាតាមអង្គភាពទាំងនោះ។
- បន្តពង្រឹងតួនាទី និងសមត្ថភាពរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិនានាក្នុងការត្រួតពិនិត្យ និងការគាំទ្រដល់កិច្ចប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ជំរុញដល់ការរៀបចំ និងការដាក់ឲ្យប្រើប្រាស់នូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធចាំបាច់នានា ដើម្បីធានាឲ្យរដ្ឋបាល

ថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការគ្រប់គ្រង និងការចាត់ចែងបុគ្គលិករបស់ខ្លួនស្របតាមតម្រូវការប្រកបដោយប្រសិទ្ធភាព។

- ពិនិត្យ និងកែសម្រួលនូវបែបផែននៃជំនួយបច្ចេកទេស តាមរយៈការកាត់បន្ថយជាបណ្តើរៗនូវជំនួយបច្ចេកទេសនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្តដោយបន្ថែមការគាំទ្រជំនួយបច្ចេកទេសដល់ថ្នាក់ក្រុង ស្រុក។

## ៤.៧. ការគ្រប់គ្រងហិរញ្ញវត្ថុ

ជារួម ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអនុវត្តកម្មវិធីជអ៣ គឺជាការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងនាម គ.ជ.អ.ប។ ប្រព័ន្ធ និងនីតិវិធីនានានៃគ្រប់គ្រងហិរញ្ញវត្ថុជអ៣ ជាពិសេសការរៀបចំសេចក្តីសម្រេចរួម និងកិច្ចព្រមព្រៀងដើម្បីអនុវត្តផែនការសកម្មភាពនិងថវិកា ប្រព័ន្ធលំហូរថវិកា ការធ្វើសវនកម្មនៅតែត្រូវបានយកមកអនុវត្តក្នុងរយៈពេលនៃការពន្យារពេលនៃជអ៣។ ដោយឡែក ដើម្បីធានាដល់ការគាំទ្រដល់ថ្នាក់ក្រុង ស្រុក ចាំបាច់តម្រូវឲ្យមានការពិនិត្យ និងការកែសម្រួលនូវប្រព័ន្ធលំហូរ និងការគ្រប់គ្រងថវិកាដែលត្រូវផ្ទេរពីថវិកាកញ្ចប់រួមរបស់ គ.ជ.អ.ប ទៅឲ្យក្រុង ស្រុកនីមួយៗសម្រាប់ការអនុវត្តកម្មវិធីជអ៣ឲ្យបានសមស្រប។

ជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០១៤ ក៏ត្រូវមានការពង្រឹងបន្ថែមនូវសមត្ថភាពសវនកម្មផ្ទៃក្នុងនៃកម្មវិធីជអ៣ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។

## ៤.៨. ការងារអន្តរវិស័យ

### ៤.៨.១. យេនឌ័រ

កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងសមភាពយេនឌ័រនឹងត្រូវបានលើកកម្ពស់ក្នុងអំឡុងឆ្នាំ២០១៤ ដោយសារតែកិច្ចការនេះមានវឌ្ឍនភាពតិចតួចនាពេលកន្លងមក។ យុទ្ធសាស្ត្រស្តីពីយេនឌ័រនៃជអ៣ នឹងត្រូវបានបន្តធ្វើជាមូលដ្ឋានក្នុងការតម្រង់ទិសសម្រាប់ឆ្នាំ២០១៤ ហើយដោយឡែកលទ្ធផលនៃការរកឃើញក្នុងការធ្វើសវនកម្មយេនឌ័រដែលនឹងត្រូវបញ្ចប់នៅខែមករា ឆ្នាំ២០១៤ នឹងត្រូវបានយកមកពិភាក្សាជាមួយស្ថាប័នអនុវត្តជអ៣នីមួយៗ ដើម្បីធានាឲ្យមានការឯកភាពគ្នាទៅលើសកម្មភាពជាក់លាក់នានាដែលត្រូវផ្តោតការយកចិត្តទុកដាក់សម្រាប់ឆ្នាំ២០១៤។

- **ការបញ្ជ្រាបយេនឌ័រទៅក្នុងអាទិភាពនានានៃកម្មវិធី**
  - ការពង្រឹងរបៀបគ្រប់គ្រងការបំពេញការងារនឹងរួមបញ្ចូលទាំងការបំពេញការងារដែលទាក់ទងទៅនឹងការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវប្រកាន់យកនូវវិធានការសមស្របដើម្បីធានាថា លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ដើម្បីគាំទ្រដល់ស្ថាប័នអនុវត្តនីមួយៗ។
  - គោលនយោបាយស្តីពីការរៀបចំថវិកាដែលឆ្លើយតបទៅនឹងយេនឌ័រ ព្រមទាំងសេចក្តីណែនាំនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគាំទ្រដល់ការប្រើប្រាស់នូវថវិកា

សាធារណៈដែលមានការឆ្លើយតបទៅនឹងយេនឌ័រ ចាំបាច់ត្រូវបានរៀបចំបញ្ចប់នៅត្រីមាសទី១នៃឆ្នាំ២០១៤

- ការរៀបចំតាក់តែងនូវក្របខ័ណ្ឌនានាស្ដីពីការត្រួតពិនិត្យ និងវាយតម្លៃត្រូវដាក់បញ្ចូលទាំងការត្រួតពិនិត្យតាមដាននូវលទ្ធផលនានាដែលឆ្លើយតបទៅនឹងយេនឌ័រ និងសមភាពយេនឌ័រផងដែរនៅក្នុង ១) ការជះឥទ្ធិពលទៅលើការធ្វើសេចក្ដីសម្រេចចុងក្រោយពាក់ព័ន្ធនឹងផែនការ និងការវិភាជថវិកា និង ២) លទ្ធភាពនៃការទទួលបានផលប្រយោជន៍នានាពីការអភិវឌ្ឍ
- បញ្ហាយេនឌ័រត្រូវបានយកចិត្តទុកដាក់នៅក្នុងការរៀបចំតាក់តែងសេចក្ដីណែនាំនានា និងការអនុវត្តសាកល្បងនានានៅមូលដ្ឋាន។
- វិធានការវិជ្ជមាននានាសំដៅលើកកម្ពស់ចំនួនស្ត្រីនៅក្នុងការជ្រើសរើស ការតែងតាំង និងការតម្លើងឋានន្តរស័ក្តិ ថ្នាក់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនឹងត្រូវបានប្រកាន់យកយ៉ាងជាក់លាក់។
- ការរៀបចំតាក់តែងនូវផអ៣ដំណាក់កាលបន្ទាប់ ត្រូវរួមបញ្ចូលនូវវិធានការនានាដើម្បីធានាថា សមភាពយេនឌ័រត្រូវបានដាក់បញ្ចូល។ ទាក់ទងនឹងបញ្ហានេះ ចាំបាច់ត្រូវមានការពិនិត្យមើលឡើងវិញទៅលើការបង្កើតនូវយន្តការដ៏សមស្របមួយដើម្បីជំរុញនូវការបញ្ជ្រាបយេនឌ័រ ព្រមទាំងវិធានការជាក់លាក់នានាដើម្បីពង្រឹងតួនាទីរបស់ក្រសួងកិច្ចការនារី។

- **ការបង្កើនភាពអង់អាចដល់ស្ត្រី**

ការបង្កើនភាពអង់អាចដល់ស្ត្រីតម្រូវឲ្យមានការយកចិត្តទុកដាក់ទៅលើ ១) ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រី និង ២) ការបង្កើតកាលានុវត្តភាព និងបរិយាកាសការងារសម្រាប់ស្ត្រី។ ចំនុចទី២នេះ មានសារៈសំខាន់បំផុតនៅក្នុងកន្លែងធ្វើការដែលមានចំនួនបុរសច្រើនលើសលប់ដែលកំពុងកើតមាននៅគ្រប់ថ្នាក់រដ្ឋបាលទាំងអស់នាពេលបច្ចុប្បន្ន។

- ទិន្នន័យដើមគ្រាតាមថ្នាក់រដ្ឋបាលនីមួយៗ នឹងត្រូវបានបង្កើតឡើងនៅដើមឆ្នាំ២០១៤ ដើម្បីតាមដានវឌ្ឍនភាព
  ក្នុងបែបផែនជាភាគរយនៃចំនួនស្ត្រីដែលត្រូវបានចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គជអប ដើម្បីធានាឲ្យមានចំនួនស្ត្រីច្រើនដែលអាចជះឥទ្ធិពលដល់កិច្ចដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងកិច្ចអភិវឌ្ឍន៍។
- បរិយាកាសការងារសម្រាប់ទាំងស្ត្រី និងបុរសចាំបាច់ត្រូវមានការគាំទ្រយ៉ាងជាក់លាក់។ ដោយឡែក បែបផែនជាក់ស្ដែងនៃការឆ្លើយតបនឹងយេនឌ័រ ព្រមទាំងការលើកកម្ពស់នូវការយល់ដឹងអំពីការទទួលខុសត្រូវរបស់បុគ្គលិកនីមួយៗ ក៏ចាំបាច់ត្រូវបានយកចិត្តទុកដាក់ផងដែរ។

### ៤.៨.២. ការប្រែប្រួលអាកាសធាតុ

ការងារអន្តរវិស័យដ៏សំខាន់មួយទៀតរបស់កម្មវិធីជាតិ គឺការបញ្ជ្រាបការកាត់បន្ថយភាពងាយរងគ្រោះ និងការបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការសកម្មភាព និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗ។ ក្នុងឆ្នាំ២០១៤ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុងការគាំទ្រដល់គម្រោងសាកល្បងស្តីពី"**រដ្ឋបាលថ្នាក់ក្រោមជាតិ និងការប្រែប្រួលអាកាសធាតុ**" ដើម្បីចងក្រង និងផ្សព្វផ្សាយមេរៀនបទពិសោធន៍ ព្រមទាំងខិតខំកៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានពីប្រភពផ្តល់មូលនិធិនានា ក្នុងគោលបំណងពង្រីកការអនុវត្តកិច្ចការនេះឱ្យកាន់តែទូលំទូលាយ។

# ផ្នែកទី៥
# ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

ក្រោមក្របខ័ណ្ឌនៃផអ៣ ទិន្នន័យយ៉ាងច្រើនត្រូវបានប្រមូល និងចងក្រងឡើងដែលក្នុងនោះរួមមានទិន្នន័យសំខាន់ៗដូចជា ទិន្នន័យស្តីពីការអនុវត្តកម្មវិធី ទិន្នន័យស្តីពីអភិបាលកិច្ច ទិន្នន័យរបស់រាជធានី និងខេត្ត ក្រុង ស្រុកនីមួយៗ ទិន្នន័យដើមគ្រាស្តីពីសមត្ថភាពក្រុង ស្រុក ខណ្ឌ ទិន្នន័យស្តីពីការអនុវត្តគម្រោងឃុំ សង្កាត់ ទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ចឃុំ សង្កាត់ ទិន្នន័យស្តីពីការកំណត់នូវបញ្ហា និងឧបសគ្គនានានៃការអនុវត្តកម្មវិធី និងទិន្នន័យស្តីពីវាយតម្លៃផលប៉ះពាល់តាមកាលកំណត់នានា។ ទិន្នន័យទាំងអស់នេះត្រូវបានដាក់បញ្ចូលនៅក្នុងគេហទំព័ររបស់គ.ជ.អ.ប។

ទោះបីយ៉ាងនេះក្តី ក៏ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនៅតែជួបប្រទះបញ្ហាប្រឈមជាច្រើន ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ព័ត៌មានទាំងនេះសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត។ បញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយសម្រាប់ឆ្នាំ២០១៤ រួមមាន (១)ការបន្តពង្រឹងបន្ថែមនូវប្រព័ន្ធ និងវិធីសាស្ត្រគ្រប់គ្រងការអនុវត្តការងារ (២)ការរៀបចំកិច្ចដំណើរការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តគោលនយោបាយ (៣)ការរៀបចំ និងការដាក់ឲ្យអនុវត្តនូវកិច្ចដំណើរការសវនកម្ម និងអធិការកិច្ចលើការអនុវត្តការងារ និង(៤)ការពិនិត្យ និងការកែសម្រួលនូវប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង (MIS) ឲ្យមានលក្ខណៈសាមញ្ញ និងងាយស្រួលក្នុងការប្រើប្រាស់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត។

ជាមួយគ្នានេះដែរ ក៏តម្រូវឲ្យមានការចូលរួមចំណែកយ៉ាងសកម្មពីគ្រប់អង្គភាពនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានានៅក្នុងការពង្រឹងកិច្ចដំណើរការតាមដានត្រួតពិនិត្យ និងវាយតម្លៃនេះផងដែរ។

- **ការពង្រឹងបន្ថែមនូវប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារ**

  ការគ្រប់គ្រងលើការអនុវត្តការងារ គឺជាកិច្ចដំណើរការមួយ ដែលជាបឋមស្ថាប័នមួយត្រូវកំណត់ពីគោលដៅ និងអាទិភាពរបស់ខ្លួន ហើយបន្ទាប់មកត្រូវធានាថាអាទិភាព និងគោលដៅទាំងនោះ ត្រូវបានសម្រេច។ ផ្អែកលើគោលដៅ និងអាទិភាពទាំងនេះ ត្រូវមានការរៀបចំជាសកម្មភាពលម្អិតនានា។ ដោយឡែក គោលដៅយ៉ាងច្បាស់លាស់ចំនួន១៥ ត្រូវបានកំណត់នៅក្នុងផអ៣ ហើយចំណុចដៅនានា ក៏បានត្រូវបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំផងដែរ។ ជាមួយគ្នានោះដែរ ប្រព័ន្ធទិន្នន័យជាច្រើន ជាពិសេស ប្រព័ន្ធទិន្ន័យគ្រប់គ្រងផែនការសកម្មភាពនិងថវិកា(NAD) ក៏ត្រូវបានបង្កើតឡើង ដើម្បីប្រមូល និងចងក្រងនូវព័ត៌មានស្តីពីការអនុវត្តការងារទាំងនេះ។ ទោះជាយ៉ាងនេះក្តី ដើម្បីពង្រឹងការគ្រប់គ្រងការអនុវត្តការងារចាំបាច់ត្រូវយកចិត្តទុកដាក់លើការបន្តពង្រឹងតួនាទី និងសមត្ថភាពរបស់ គ.ជ.អ.ប ក្នុងការគ្រប់គ្រងផ្អែកលើលទ្ធផល ព្រមទាំងការរៀបចំឲ្យមានកិច្ចប្រជុំ ការពិគ្រោះយោបល់ និងវេទិកាពិភាក្សាអំពីគោលដៅ ចំណុចដៅ និងលទ្ធផលនានាជាប្រចាំ។

- **ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃគោលនយោបាយ**

សៀវភៅណែនាំស្តីពីការតាមដានត្រួតពិនិត្យ និងការវាយតម្លៃគោលនយោបាយ ត្រូវបានរៀបចំជាសេចក្តីព្រាងរួចហើយ ហើយរំពឹងថានឹងត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់នៅឆ្នាំ២០១៤។ សៀវភៅណែនាំនេះ កំណត់អំពីក្របខ័ណ្ឌការងារមួយសម្រាប់ការវាស់វែងអំពីកម្រិតស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការអង្កេតនានាអំពីកម្រិតនៃភាពពេញចិត្តលើគោលនយោបាយ ការពិនិត្យឡើងវិញតាមប្រធានបទសំខាន់ៗ ការរៀបចំនីតិវិធីយ៉ាងច្បាស់លាស់អំពីការតាមដានត្រួតពិនិត្យលើការរៀបចំគោលនយោបាយ និងការវាយតម្លៃលើផលប៉ះពាល់។

- **កិច្ចដំណើរការសវនកម្ម និងអធិការកិច្ច**

  ទោះបីជាអង្គភាពតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់លេខាធិការដ្ឋានគ.ជ.អ.ប អាចផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំនីតិវិធីឲ្យមានលក្ខណៈជាប្រព័ន្ធសម្រាប់ការត្រួតពិនិត្យមើលពីលើ និងការធានាឲ្យមានការអនុវត្តតាមល័ក្ខខ័ណ្ឌកំណត់ ក៏ប៉ុន្តែការដឹកនាំកិច្ចការនេះនៅតែជាតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។ ឯកសារទស្សនទានដែលពិពណ៌នាអំពីកិច្ចដំណើរការ និងជម្រើសនានាសម្រាប់ការរៀបចំស្ថាប័នត្រូវបានរៀបចំនៅក្នុងឆ្នាំ២០១២។ ទិន្នន័យស្តីពីការអនុវត្តតាមល័ក្ខខ័ណ្ឌកំណត់ គឺជាឧបករណ៍សម្រាប់ការតាមដានត្រួតពិនិត្យដ៏ចាំបាច់មួយ ដើម្បីវាស់វែងពីកម្រិតនៃការអនុវត្តគោលនយបាយ និងលិខិតបទដ្ឋានគតិយុត្តនានា។ ដោយឡែក សូចនាករនៃការអនុវត្តតាមល័ក្ខខ័ណ្ឌកំណត់ រួមបញ្ចូលទាំងទិន្នន័យលទ្ធកម្ម និងហិរញ្ញវត្ថុ ព្រមទាំងអធិការកិច្ចគម្រោងដែលបានកំណត់យ៉ាងច្បាស់នៅក្នុងក្របខ័ណ្ឌលទ្ធផលនៃផអ៣ នឹងត្រូវប្រើប្រាស់សម្រាប់"**ការត្រួតពិនិត្យមើលពីលើ និងការត្រួតពិនិត្យនីត្យានុកូលភាព**" ដោយក្រសួង ស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលជារួមដោយអនុកម្មវិធីទី២។

- **ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង**

  ក្នុងអំឡុងពេលនៃការអនុវត្តផអ៣ ប្រព័ន្ធ និងទិន្នន័យជាច្រើនត្រូវបានរៀបចំជាបន្តបន្ទាប់។ ទោះជាយ៉ាងណាក៏ដោយ ក៏ប្រព័ន្ធនេះមួយចំនួននៅមានភាពខ្វះខាត ឬមានលក្ខណៈត្រួតស៊ីគ្នា។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងសហការជាមួយក្រសួងផែនការ ដើម្បីកំណត់អំពីតួនាទីរបស់ស្ថាប័នឲ្យបានច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងនិរន្តរភាពនៃប្រព័ន្ធ សំដៅរៀបចំបង្កើតប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងឲ្យមានលក្ខណៈសមស្រប និងសាមញ្ញសម្រាប់ឆ្នាំ២០១៤។

# ផ្នែកទី៦

## ថវិកាប៉ាន់ស្មានសម្រាប់កម្មវិធី និងប្រភពហិរញ្ញប្បទាន

ថវិកាប៉ាន់ស្មាននៃផអ៣ត្រូវបានគណនាដោយផ្អែកតាមប្រភេទចំណាយធំៗចំនួន២ គឺ(១)ថវិកាចំណាយសម្រាប់ការអភិវឌ្ឍសមត្ថភាព ប្រតិបត្តិការកម្មវិធី និងជំនួយបច្ចេកទេស និង(២)ជំនួយហិរញ្ញវត្ថុដែលត្រូវផ្តល់សម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ទាំងអស់ ក្រោមក្របខ័ណ្ឌនៃយន្តការផ្ទេរមូលនិធិ និងហិរញ្ញប្បទាននានា។ ចំពោះថវិកាចំណាយសម្រាប់ប្រភេទទី១ ដែលមានចំនួនស្ទើរតែទាំងអស់បានមកពីការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ មានលក្ខណៈសំខាន់បំផុតសម្រាប់ការរៀបចំ និងការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធ និងនីតិវិធីលម្អិតនានាដើម្បីជួយគាំទ្រ និងធានាសុវត្ថិភាពដល់ការគ្រប់គ្រង និងការប្រើប្រាស់ថវិកាចំណាយក្នុងប្រភេទទី២ ដែលភាគច្រើនជាថវិការបស់រាជរដ្ឋាភិបាល និងហិរញ្ញប្បទានរបស់គម្រោងដោយឡែកពាក់ព័ន្ធនានា។

### ៦.១. ថវិកាផអ៣សម្រាប់អភិវឌ្ឍសមត្ថភាព ប្រតិបត្តិការកម្មវិធី និងជំនួយបច្ចេកទេស

តារាងខាងក្រោមឆ្លុះបញ្ចាំងអំពីការចំណាយជាក់ស្តែងសម្រាប់ការអភិវឌ្ឍសមត្ថភាព ប្រតិបត្តិការកម្មវិធី និងជំនួយបច្ចេកទេសប្រៀបធៀបទៅនឹងគម្រោងថវិកាប្រចាំឆ្នាំនីមួយៗ (ឆ្នាំ២០១១ដល់ឆ្នាំ២០១៣) ដែលគាំទ្រដោយថវិកាកញ្ចប់រួម និងចូលរួមចំណែកជាថវិការបស់គម្រោងដៃគូអភិវឌ្ឍន៍មួយចំនួន។ តួលេខក្នុងតារាងបានបង្ហាញឲ្យឃើញថា ថវិកាចំណាយសម្រាប់ឆ្នាំ២០១១ មានចំនួនតិចជាងថវិកាចំណាយឆ្នាំ២០១២ និង២០១៣។ មូលហេតុនៃការចំណាយតិចនេះ(៥៤%) គឺដោយសារការចាប់ផ្តើមអនុវត្តផអ៣ក្នុងឆ្នាំ២០១១ មានការយឺតយ៉ាវអស់រយៈពេលចំនួន៦ខែ។ ក្នុងឆ្នាំ២០១២ ការចំណាយសម្រាប់ជំនួយបច្ចេកទេស និងចំណាយសម្រាប់បុគ្គលិកបានកើនឡើងខ្ពស់ដោយសារគិតបញ្ចូលទាំងការចំណាយសម្រាប់ប្រតិបត្តិការអាទិភាព(POC)ផងដែរ។ ក្នុងឆ្នាំ២០១៣ ថវិកាចំណាយមានចំនួនតិចជាងឆ្នាំមុនៗ ដោយសារមានការថយចុះនៃការចូលរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ទៅក្នុងកញ្ចប់ថវិការួមរបស់ផអ៣ ដែលក្នុងនោះការចំណាយសម្រាប់៦ខែដើមឆ្នាំមានកម្រិតទាបខ្លាំងដោយសារភាពរអាក់រអួលនៃការផ្ទេរថវិកាពីដៃគូអភិវឌ្ឍន៍។

តារាងទី១ ៖ ការចំណាយសម្រាប់អភិវឌ្ឍន៍សមត្ថភាព ប្រតិបត្តិការ និងជំនួយបច្ចេកទេស
(គិតជាដុល្លារ)

| ការបរិយាយ | ២០១១ | | | ២០១២ | | | ២០១៣ (មករា-មិថុនា) | | |
|---|---|---|---|---|---|---|---|---|---|
| | ថវិកាគ្រោង | ចំណាយ | % | ថវិកាគ្រោង | ចំណាយ | % | ថវិកាគ្រោង | ចំណាយ | % |
| សកម្មភាពកម្មវិធី | 11.866.868 | 4.936.351 | 42% | 9.774.048 | 7.701.157 | 79% | 3.315.959 | 469.032 | 14% |
| ទីប្រឹក្សានិងបុគ្គល | 4.406.581 | 2.345.482 | 53% | 8.035.127 | 7.450.499 | 93% | 5.933.621 | 2.822.310 | 48% |
| ប្រតិបត្តិការ | 2.519.534 | 2.250.068 | 89% | 2.928.168 | 2.667.599 | 91% | 2.633.783 | 1.113.372 | 42% |
| សម្ភារៈបរិក្ខារ | 2.635.729 | 2.055.750 | 78% | 564.043 | 511.951 | 91% | 99.802 | 9.646 | 10% |
| សរុប | **21.428.712** | **11.587.651** | **54%** | **21.301.386** | **18.331.206** | **86%** | **11.983.165** | **4.414.360** | **37%** |

## ៦.២. ការផ្តល់ហិរញ្ញប្បទានតាមរយៈយន្តការនៃការផ្ទេរហិរញ្ញប្បទានអន្តររដ្ឋបាលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

កំណែទម្រង់នៅថ្នាក់ក្រោមជាតិបានតម្រូវឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានថវិការបស់ខ្លួន។ មកដល់បច្ចុប្បន្ននេះ សមិទ្ធផលដែលសម្រេចបានគួរឲ្យកត់សម្គាល់ពាក់ព័ន្ធនឹងយន្តការនៃការផ្ទេរហិរញ្ញប្បទានអន្តររដ្ឋបាល គឺការរៀបចំបង្កើត និងការដាក់ឲ្យអនុវត្តនូវមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក។ ការរៀបចំបង្កើតនូវមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក បានធ្វើឲ្យរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាល ក្រុង ស្រុកក្លាយទៅជារដ្ឋបាលថ្នាក់ថវិកាថ្មី និងបានបង្កលក្ខណៈឲ្យថ្នាក់រដ្ឋបាលទាំងនេះមានលទ្ធភាពក្នុងការអនុវត្តនូវមុខងារជាជម្រើសក្នុងក្របខ័ណ្ឌនៃអាណត្តិទូទៅរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការរៀបចំឲ្យមានកញ្ចប់ថវិការួមរបស់ជអ៣ ដែលបានមកពីការចូលរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ ក៏បានដើរតួយ៉ាងសំខាន់ក្នុងការធ្វើឲ្យសម្រេចបាននូវសមិទ្ធផលខាងលើ តាមរយៈការរៀបចំបង្កើតគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ប្រព័ន្ធកសាងផែនការ និងប្រព័ន្ធរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកិច្ចដំណើរការអនុវត្តផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រោមក្របខ័ណ្ឌនៃជអ៣ ការផ្ទេរហិរញ្ញប្បទានអន្តររដ្ឋបាលពីឆ្នាំ២០១១ដល់២០១៣ មានចំនួនប្រមាណ**៤៥០លានដុល្លារ** ដែលក្នុងនោះ៨៩% (ឬប្រមាណ៤០០លានដុល្លារ) គឺជាការផ្ទេរមកពីថវិកាជាតិនិងថវិកាប្រមាណ១១% (ឬប្រមាណ៥០លានដុល្លារ) ជាថវិកាចូលរួមចំណែករបស់ដៃគូអភិវឌ្ឍន៍។ ថវិកាវិភាជន៍ និងការផ្ទេរជាក់ស្តែងសម្រាប់រយៈពេល៣ឆ្នាំនេះមានឆ្លុះបញ្ចាំងនៅក្នុងតារាងដូចខាងក្រោម។

**តារាងទី២ ៖ ការផ្ទេរហិរញ្ញប្បទានអន្តររដ្ឋបាលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១-២០១៣**

**(គិតជាដុល្លារ)**

| ល.រ | ថវិកាថ្នាក់ក្រោមជាតិ | ២០១១ | | ២០១២ | | ២០១៣ | |
|---|---|---|---|---|---|---|---|
| | | ថវិកាគ្រោង | ចំណាយ | ថវិកាគ្រោង | ចំណាយ | ថវិកាគ្រោង | ចំណាយ(៦ខែ) |
| 1 | មូលនិធិឃុំ សង្កាត់ | 38.300.000 | 24.931.183 | 44.935.802 | 40.995.248 | 50.851.635 | 9.109.199 |
| 2 | មូលនិធិក្រុង ស្រុក | 15.000.000 | គ្មានទិន្នន័យ | 13.000.000 | 9.158.500 | 18.679.877 | 5.052.586 |
| 3 | ថវិកាអភិវឌ្ឍន៍រាជធានី ខេត្ត | គ្មានទិន្នន័យ | គ្មានទិន្នន័យ | 93.957.900 | 66.193.339 | 124.001.235 | 53.253.887 |
| សរុប | | | | **151.893.702** | **116.347.087** | **193.532.747** | **67.415.672** |

ក្នុងឆ្នាំ២០១៣ រួមមានថវិកាចំនួន៤លានដុល្លារ ជាថវិកាចូលរួមចំណែករបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ស៊ុយអែដ (Sida) ទៅក្នុងមូលនិធិក្រុង ស្រុក ក្រៅពីនេះថវិកាដែលបានផ្ទេរទាំងអស់ គឺជាថវិកាជាតិរបស់រាជរដ្ឋាភិបាល។

## ៦.៣. គម្រោងពាក់ព័ន្ធផ្សេងៗទៀត (គម្រោងជាច់ដោយឡែក)

ក្រៅពីការអនុវត្តនូវតួនាទីដ៏សំខាន់ក្នុងការបង្កលក្ខណៈ ការត្រួតពិនិត្យ និងការធានាសុវត្ថិភាពនូវការគ្រប់គ្រង និងការប្រើប្រាស់ហិរញ្ញវត្ថុខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានសម្របសម្រួល

និងគ្រប់គ្រងគម្រោងដាច់ដោយឡែកពាក់ព័ន្ធនានា ដែលបានចូលរួមចំណែកក្នុងការគាំទ្រកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងទម្រង់ជាថវិកា និងមិនមែនថវិកា ដូចជា គម្រោង UNICEF-SETH KOMA, UN-WOMEN គម្រោងបែងចែកដីសម្បទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច(WB-LASED) គម្រោងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់បឹងទន្លេសាប(ADB-TSPRSP) គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ(UNCDF-LGCC) គម្រោងការិយាល័យច្រកចេញចូលតែមួយដែលជាសមាសភាគមួយនៃគម្រោងអភិបាលកិច្ចមូលដ្ឋាន (WB-DFGG) គម្រោងJICA-PILACII គម្រោងEU-SPACE, គម្រោងUNDP-ACCESS គម្រោង UNFPA ដែលមានថវិកាប្រចាំឆ្នាំសរុបប្រមាណពី៧-១២លានដុល្លារក្នុងមួយឆ្នាំៗ។

## ៦.៤. ផែនការចំណាយ និងការផ្តល់ហិរញ្ញប្បទានរបស់គអព ឆ្នាំ២០១៤ (កញ្ចប់ថវិការួម)

សម្រាប់ឆ្នាំ២០១៤ រួមមានអាទិភាពតាមវិស័យយ៉ាងច្បាស់លាស់ដែលត្រូវខិតខំប្រឹងប្រែងរៀបចំផែនការសកម្មភាពយ៉ាងជាក់លាក់ ដោយមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការអនុវត្តអាទិភាពទាំងនោះ។ ការយកចិត្តទុកដាក់ជាសំខាន់ គឺផ្តោតទៅលើការគាំទ្រដល់ក្រុង ស្រុក និងឃុំ សង្កាត់ តាមរយៈការពង្រឹង និងការពង្រីកការផ្តល់សេវាទីប្រឹក្សា សេវាពិគ្រោះយោបល់ និងសេវាគាំទ្រផ្នែកបច្ចេកទេសនានាដោយផ្អែកតាមតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

**តារាងទី៣ ៖ ការប៉ាន់ស្មានការចំណាយ និងការផ្តល់ហិរញ្ញទានឆ្នាំ២០១៤**
**(ថវិកាកញ្ចប់រួម គិតជាដុល្លារ)**

| ល.រ | បរិយាយ | ថវិកា | | ប្រៀបធៀប |
|---|---|---|---|---|
| | | ២០១៣ | ២០១៤ | |
| 1 | សកម្មភាពកម្មវិធី | 3.315.959 | 3.600.000 | 284.041 |
| 2 | ទីប្រឹក្សា និងបុគ្គលិក | 6.100.000 | 5.700.000 | (400.000) |
| 3 | ប្រតិបត្តិការ | 2.633.783 | 2.700.000 | 66.217 |
| 4 | លទ្ធកម្មសម្ភារៈ បរិក្ខារ | 99.802 | 500.000 | 400.198 |
| សរុប | | **12.149.544** | **12.500.000** | **350.456** |

- **សកម្មភាពកម្មវិធីនានា**
  ថវិកាចំណាយប៉ាន់ស្មានសម្រាប់ប្រភេទសកម្មភាពកម្មវិធីនឹងត្រូវប្រើប្រាស់សម្រាប់សកម្មភាព និងព្រឹត្តិការណ៍នានាដូចជា សិក្ខាសាលា ការពិភាក្សា ការពិគ្រោះយោបល់ អំពីមេរៀន និងបទពិសោធន៍នានា ការរៀបចំគអពដំណាក់កាលបន្ទាប់ និងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនានា។

- **ទីប្រឹក្សា និងបុគ្គលិក**
  ផ្អែកលើស្ថានភាពបច្ចុប្បន្នពាក់ព័ន្ធនឹងសមត្ថភាពរបស់ស្ថាប័នរបស់រដ្ឋបាលទាំងនៅថ្នាក់

ជាតិ និងថ្នាក់ក្រោមជាតិ និងដើម្បីធានាបាននូវការពង្រឹងភាពម្ចាស់ការរបស់រាជរដ្ឋាភិបាលក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការផ្តល់ជំនួយបច្ចេកទេសនៅតែជាតម្រូវការចាំបាច់ក្នុងរយៈពេលមធ្យមមួយបន្ថែមទៀត។ ទោះជាយ៉ាងនេះក៏ដោយ ក៏គម្រោងថវិកាចំណាយសម្រាប់ទីប្រឹក្សាសម្រាប់ឆ្នាំ២០១៤ នឹងត្រូវថយចុះ ក៏ប៉ុន្តែថវិកាចំណាយសម្រាប់បុគ្គលិកកិច្ចសន្យានឹងត្រូវកើនឡើង ដើម្បីធ្វើឲ្យស្របទៅនឹងយុទ្ធសាស្ត្រនៃការកាត់បន្ថយជាបណ្តើរៗនូវចំនួនទីប្រឹក្សា និងដើម្បីផ្តោតការយកចិត្តទុកដាក់ទៅលើការគាំទ្រដល់ថ្នាក់ក្រុង ស្រុក ខណ្ឌតាមរយៈការបន្ថែមនូវចំនួនបុគ្គលិកកិច្ចសន្យា។ ជាទូទៅ ថវិកាសម្រាប់ជំនួយបច្ចេកទេសសម្រាប់ឆ្នាំ២០១៤មានការថយចុះចំនួនប្រមាណ៤០០.០០០ ដុល្លារធៀបនឹងឆ្នាំ២០១៣។

- **ប្រតិបត្តិការ**

ចំណាយប្រតិបត្តិការនឹងផ្តោតជាសំខាន់ទៅលើការចុះតាមដានត្រួតពិនិត្យ វាយតម្លៃ និងការងារត្រួតពិនិត្យមើលពីលើ ការរៀបចំកិច្ចប្រជុំពិភាក្សា ការប្រមូលចងក្រងឯកសារ ការចំណាយទៅលើប្រេងឥន្ធនៈ ការថែទាំ និងជួសជុលសម្ភារៈ បរិក្ខា និងមធ្យោបាយធ្វើដំណើរព្រមទាំងការផ្គត់ផ្គង់សម្ភារៈការិយាល័យ។

- **លទ្ធកម្មសម្ភារៈ និងបរិក្ខារ**

ដោយទទួលស្គាល់ថា មានតម្រូវការចាំបាច់ឲ្យមានការផ្លាស់ប្តូរយានយន្ត និងឧបករណ៍នានាបន្ថែមទៀតសម្រាប់ការអនុវត្តការងារ អាស្រ័យហេតុនេះ ថវិកាចំណាយសម្រាប់លទ្ធកម្មឧបករណ៍ទាំងនេះក្នុងឆ្នាំ២០១៤ ត្រូវបានគ្រោងក្នុងចំនួនថវិកាដ៏សមស្របមួយ។ យ៉ាងណាមិញ ការរៀបចំផអ៣ដំណាក់កាលបន្ទាប់ក៏នឹងត្រូវបន្តផ្តោតការគិតគូរឲ្យបានហ្មត់ចត់អំពីបញ្ហានេះផងដែរ។

- **ប្រភពហិរញ្ញប្បទាន**

លេខាធិការដ្ឋាន គ.ជ.អ.ប នឹងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងការកៀរគរធនធាន ដើម្បីឆ្លើយតបបានទៅនឹងគម្រោងថវិកាចំណាយនានា ដូចបានធ្វើការប៉ាន់ស្មានខាងលើ។ ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធសំខាន់ៗដែលចូលរួមចំណែកក្នុងកញ្ចប់ថវិការួមរបស់គ.ជ.អ.ប ក្នុងឆ្នាំ២០១៣ ដែលក្នុងនោះរួមមាន សហភាពអឺរ៉ុប ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ និងទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍស្វីស នឹងត្រូវបានស្នើសុំឲ្យរក្សា ឬបង្កើនការចូលរួមចំណែកផ្តល់ហិរញ្ញប្បទានទៅក្នុងកញ្ចប់ថវិការួម។ ជាមួយគ្នានោះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងខិតខំសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងទៀត តាមរយៈយន្តការនៃក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងតាមរយៈការប្រាស្រ័យទាក់ទងដោយផ្ទាល់។

## ផ្នែកទី៧

## ដំណើរការរៀបចំផអ៣ ដំណាក់កាលបន្ទាប់

ទោះបីជាឯកសារអផ៣មានលក្ខណៈទូលំទូលាយ និងល្អិតល្អន់យ៉ាងណាក៏ដោយ ក៏ការយល់ដឹងទៅលើខ្លឹមសារឯកសាររបស់តួអង្គពាក់ព័ន្ធនានាក្នុងការអនុវត្តផអ៣នេះ ក៏នៅតែមានកម្រិតនៅឡើយ ដែលនេះក៏ជាហេតុផលមួយក្នុងការមិនអាចសម្រេចបានលទ្ធផលរំពឹងទុកតាមពេលវេលាផងដែរ។

យោងតាមហេតុផលនេះ អនុកម្មវិធីនីមួយៗបានទទួលស្គាល់ថា ភាពជាម្ចាស់សម្រាប់កម្មវិធីកំណែទម្រង់នៅមានភាពទន់ខ្សោយ។ តាមរយៈការប្រជុំធ្វើផែនការ និងពិនិត្យឡើងវិញដែលធ្វើជាមួយនឹងស្ថាប័នអនុវត្តទាំងអស់ ភាពជាម្ចាស់ត្រូវបានកំណត់យ៉ាងតិចក្នុងពីរកម្រិត។ កម្រិតទីមួយពាក់ព័ន្ធនឹងស្ថាប័នអនុវត្តអនុកម្មវិធី (រួមទាំងក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នផងដែរ) ហើយកម្រិតមួយទៀតពាក់ព័ន្ធជាមួយស្ថាប័នសាមី។

កិច្ចដំណើរការរៀបចំតាក់តែងអផ៣ដំណាក់កាលបន្ទាប់ ចាំបាច់ត្រូវមានការកែលំអ ប្រសិនបើភាពជាម្ចាស់ទាំងពីរកម្រិតនេះជាកត្តាចាំបាច់។ ក្នុងការអនុវត្តការពិភាក្សា និងការអនុម័តនៃផែនការទាំងនោះ នឹងត្រូវធ្វើនៅទាំងពីរកម្រិត។

លេខាធិការដ្ឋានគ.ជ.អ.ប នឹងចាប់ផ្តើមពិភាក្សាអំពីកិច្ចដំណើរការរៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់ បន្ទាប់ពីឯកសារពន្យារពេលនៃអផ៣នេះ និងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៤ត្រូវបានអនុម័ត និងផ្សព្វផ្សាយសម្រាប់ការអនុវត្ត។ ជាក់ស្តែង ក្រុមការងារបច្ចេកទេសសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនឹងត្រូវជួបប្រជុំគ្នាដើម្បីកំណត់អំពីជម្រើសនានា និងរៀបចំល័ក្ខខ័ណ្ឌការងារសម្រាប់កិច្ចដំណើរការរៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់នៅខែមករា ឆ្នាំ២០១៤ សំដៅធានាឲ្យកិច្ចដំណើរការរៀបចំតាក់តែងនេះអាចចាប់ផ្តើមនៅត្រីមាសទី១នៃឆ្នាំ២០១៤។ ក្នុងកិច្ចដំណើរការរៀបចំតាក់តែងនេះ ក៏ត្រូវបានរំពឹងផងដែរថា នឹងមានការពិភាក្សាយ៉ាងស៊ីជម្រៅ និងមានការព្រមព្រៀងពីអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់។ អ្នកសម្របសម្រួល និងជំនួយបច្ចេកទេសខាងក្រៅ និងឯករាជ្យនឹងត្រូវបានកៀរគរ។

# ផ្នែកទី៨

## ការធ្វើបច្ចុប្បន្នភាពលើការសន្មត និងហានិភ័យនានារបស់ ផអ៣

ឯកសារផអ៣បានកំណត់ការសន្មត និងហានិភ័យនៅក្នុង៥ប្រភេទសំខាន់ៗគឺៈ

១. ការសន្មត និងហានិភ័យពាក់ព័ន្ធនឹងការអភិវឌ្ឍគោលនយោបាយ

២. ការសន្មត និងហានិភ័យពាក់ព័ន្ធនឹងតួនាទីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា

៣. ការសន្មត និងហានិភ័យពាក់ព័ន្ធនឹងប្រព័ន្ធ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ការសន្មត និងហានិភ័យពាក់ព័ន្ធនឹងការផ្តល់មូលនិធិ និងការរៀបចំបុគ្គលិក

៥. ការសន្មត និងហានិភ័យពាក់ព័ន្ធនឹងការរៀបចំតាក់តែងកម្មវិធី

តារាងខាងក្រោមនេះនឹងបង្ហាញការពិនិត្យមើលឡើងវិញលើការសន្មតនានាដែលបានកំណត់ក្នុងឯកសារផអ៣ និងវាយតម្លៃជាថ្មីអំពីកម្រិតនៃហានិភ័យ ព្រមទាំងកំណត់នូវវិធានការនានាដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងពេលនៃការពន្យារពេលនៃផអ៣នេះ ដើម្បីបន្ថយនូវកម្រិតនៃហានិភ័យទាំងនោះ។

| ការសន្មតនៃផអ៣ | កម្រិតនៃហានភ័យ | ដំណោះស្រាយនានា |
|---|---|---|
| **ការសន្មតនានាដែលទាក់ទងនឹងការអភិវឌ្ឍគោលនយោបាយ** | | |
| ១. តួនាទីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប គឺផ្តោត ទៅលើការរៀបចំគោលនយោបាយ និងការសម្របសម្រួល ដោយឡែកក្រសួង ស្ថាប័នពាក់ព័ន្ធនានាទទួលខុសត្រូវក្នុងការអនុវត្ត។<br>*(កម្រិតហានិភ័យកំណត់ក្នុងផអ៣ៈមធ្យម-ខ្ពស់)* | ទាប | លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពវិភាគ និងអភិវឌ្ឍគោលនយបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបានកែសម្រួល។ ទោះយ៉ាងនេះក្តី តួនាទី របស់ លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការពិនិត្យឡើងវិញ លិខិតបទដ្ឋានគតិយុត្តតាមវិស័យនានា (ឲ្យមានលក្ខណៈស្របទៅនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ) ពុំទាន់មានលក្ខណៈល្អប្រសើរនៅឡើយ។ លទ្ធភាពរបស់ គ.ជ.អ.ប និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍគោលនយោបាយនៅមានបញ្ហាប្រឈមនៅឡើយ។ |
| ២. ការកំណត់ឱ្យបានច្បាស់រវាងតួនាទីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងតួនាទី របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ នានា ជាពិសេសតួនាទីរបស់ក្រសួងមហាផ្ទៃ។<br>*(កម្រិតហានិភ័យកំណត់ក្នុងផអ៣ៈទាប)* | ទាប | |
| ៣. លេខាធិការដ្ឋាន គ.ជ.អ.ប អាចមានលទ្ធភាពក្នុងការ | ខ្ពស់ | នេះ គឺជាការ សន្មតដែលមានសារៈសំខាន់បំផុត។ |

| ការសន្មតនៃផអ៣ | កម្រិតនៃហានភ័យ | ដំណោះស្រាយនានា |
|---|---|---|
| អនុវត្តនូវសមត្ថកិច្ចរបស់ខ្លួនក្នុងការរៀបចំគោលនយោបាយដោយមិនមានភាពប្រទាំងប្រទើសជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ *(កម្រិតហានិភ័យកំណត់ក្នុងផអ៣៖មធ្យម)* | | នៅក្នុងទិដ្ឋភាពមួយចំនួនបានបង្ហាញឲ្យឃើញថា មានចក្ខុវិស័យផ្អែកគោលនយោបាយផ្សេងៗគ្នារវាងក្រសួង ស្ថាប័នពាក់ព័ន្ធ នៅក្នុងការអភិវឌ្ឍប្រព័ន្ធផ្ទេរមូលនិធិ និងការគ្រប់ គ្រងហិរញ្ញវត្ថុ ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ និងមុខងារនៃការត្រួតពិនិត្យមើលពីលើ។ ដូចបានបរិយាយនៅក្នុងឯកសារពន្យារពេលនៃផអ៣នេះ នៅពេលដែលមានទស្សនៈផ្សេងៗរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាកើតឡើង តម្រូវឲ្យមានការពង្រឹងតួនាទីរបស់ គ.ជ.អ.ប ក្នុងការសម្របសម្រួល និងការគ្រប់គ្រងលើការអនុវត្តការងារ។ |
| ៤. ការធ្វើសុខដុមនីយកម្មជាមួយនឹងគោលនយោបាយកំណែទម្រង់នានា ដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ មធ្យម)* | ទាប | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈត្រូវបានរំសាយនាពេលថ្មីៗកន្លងមកនេះ ហើយកម្មវិធីកំណែទម្រង់នេះត្រូវបានផ្ទេរឲ្យទៅស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងមុខងារសាធារណៈ។ អាស្រ័យក្រសួងមុខងារសាធារណៈ គឺជាស្ថាប័នអនុវត្តអនុកម្មវិធីទី៣នៃផអ៣ ដូចនេះការងារដែលពាក់ព័ន្ធនឹងការងារកំណែទម្រង់ការគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានរំពឹងថាមានដំណើរការដោយរលូន។ ជាមួយនេះដែរ ទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងត្រូវមានការពង្រឹងបន្ថែមទៀត ព្រមទាំងត្រូវមានការ ផ្តោតការយកចិត្តទុកដាក់នៅក្នុងឆ្នាំ២០១៤។ |
| **ការសន្មតនានាដែលទាក់ទងនឹងតួនាទីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ** | | |
| ១. ក្រសួង ស្ថាប័នទទួលស្គាល់នូវស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយនឹងធ្វើការផ្លាស់ប្តូរពីការត្រួតពិនិត្យផ្នែករដ្ឋបាលទៅជាការត្រួតពិនិត្យនីត្យានុកូលភាព។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖មធ្យម-ខ្ពស់)* | ខ្ពស់ | យន្តការពិនិត្យមើលពីលើ និងត្រួតពិនិត្យនីត្យានុកូលភាពពុំទាន់ត្រូវបានរៀបចំឲ្យច្បាស់លាស់ ហើយប្រព័ន្ធគ្រប់គ្រងនានាដែលបានអភិវឌ្ឍឡើងរហូតមកដល់ពេលនេះក៏នៅពុំទាន់បានផ្តល់នូវស្វ័យភាពពេញលេញ ដល់រដ្ឋបាលថ្នាក់ ក្រោមជាតិនៅឡើយ។ ហេតុដូច្នេះ ការអភិវឌ្ឍនីតិវិធីពិនិត្យមើលពីលើ និងត្រួតពិនិត្យនីត្យានុកូលភាព គឺជាអាទិភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងឆ្នាំ២០១៤។ បញ្ហាប្រឈមពាក់ព័ន្ធនឹងស្វ័យភាពរបស់រដ្ឋបាល |

| ការសន្ទតនៃផអ៣ | កម្រិតនៃហានភ័យ | ដំណោះស្រាយនានា |
|---|---|---|
| | | ថ្នាក់ក្រោមជាតិនឹងត្រូវបានដោះស្រាយនៅក្នុងកិច្ចដំណើរការអភិវឌ្ឍគោលនយោបាយ ដែលមានបរិយាយនៅក្នុងការសន្ទតទី៣។ |
| ២. ក្រសួង ស្ថាប័នមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចាប់ផ្តើមអនុវត្តអាណត្តិរបស់ខ្លួនក្នុងការគាំទ្រ និងត្រួតពិនិត្យនីត្យានុកូលភាព។<br>*(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣ គឺខ្ពស់)* | ខ្ពស់ | ដូចខាងលើ |
| ៣. ការអនុវត្តកម្មវិធីដោយប្រើប្រព័ន្ធនានារបស់រដ្ឋាភិបាល។<br>*(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖មធ្យម)* | មធ្យម | សកម្មភាពស្ទើរតែទាំងអស់នៃកម្មវិធីនៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានអនុវត្តដោយប្រព័ន្ធនានារបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងនេះក្តី ក៏សកម្មភាពនានានៃផអ៣ត្រូវបានគាំទ្រហិរញ្ញប្បទាន និងត្រូវធ្វើរបាយការណ៍ក្រៅប្រព័ន្ធរបស់រដ្ឋាភិបាល និងគម្រោងដាច់ដោយឡែកៗភាគច្រើនពុំទាន់ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធនានារបស់រាជរដ្ឋាភិបាល ឬពុំទាន់ត្រូវបានដាក់បញ្ចូលទៅក្នុងបែបផែននៃកញ្ចប់ថវិការួមនៅឡើយ។ |
| ៤. ការរៀបចំប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឡើងដោយមានការពិគ្រោះយោបល់ និងការចូលរួមពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។<br>*(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ទាប - មធ្យម)* | ទាប | កំពុងត្រូវបានអនុវត្ត |
| ៥. អាជ្ញាធរសេវនកម្មជាតិមានសមត្ថភាពសមស្របសម្រាប់អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។<br>*(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ខ្ពស់)* | ខ្ពស់ | លទ្ធផលរំពឹងទុកភាគច្រើនពាក់ព័ន្ធនឹងអាជ្ញាធរសវនកម្មជាតិពុំត្រូវបានអនុវត្តនៅឡើយ ក៏ប៉ុន្តែភាពអវិជ្ជមានមួយចំនួនក៏ពាក់ព័ន្ធទៅនឹងការយឺតយ៉ាវក្នុងការរៀបចំ និងដាក់ឲ្យប្រតិបត្តិនៃមូលនិធិក្រុង ស្រុកផងដែរ។ |
| ៦. ក្រសួង ស្ថាប័នចូលរួមក្នុងការរៀបចំបែបផែនសម្រាប់ការផ្ទេរមុខងារឲ្យទៅ រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>*(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣ ៖ មធ្យម)* | ខ្ពស់ | ការសន្ទតនេះកំពុងក្លាយជាការសន្ទតដែលមានកម្រិតហានិភ័យខ្ពស់។ នៅក្នុងផអ៣ជំហានបន្ទាប់នឹងត្រូវមានការពិនិត្យមើលលើកិច្ចដំណើរការផ្ទេរមុខងារក្នុងគោលបំណងបង្កើនការចូលរួម និងគាំទ្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ កិច្ចប្រជុំកម្រិតខ្ពស់មួយរបស់អ្នកដឹកនាំនយោបាយនឹងត្រូវរៀបចំឡើង ដើម្បីពិភាក្សា និងកំណត់មុខងារមួយចំនួនដែលត្រូវផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្តោតការយកចិត្តជាថ្មីទៅលើអាណត្តិទូទៅត្រូវបាន |

| ការសន្មតនៃផអ៣ | កម្រិតនៃហានភ័យ | ដំណោះស្រាយនានា |
|---|---|---|
| | | ប្រកាន់យក ហើយជាមួយគ្នានេះដែរ លិខិតបទដ្ឋាន ឬ សេចក្តីណែនាំស្តីពីមុខងារជាជម្រើសក៏កំពុងត្រូវបានអភិវឌ្ឍឡើង។ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍនានា ការរៀបចំ និងអនុវត្តគម្រោងសាកល្បងនៃការផ្ទេរមុខងារក៏ត្រូវបានគ្រោងឡើងផងដែរ។ |
| **ការសន្មតនានាដែលទាក់ទងនឹងប្រព័ន្ធ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | |
| ១. រដ្ឋបាលនានានៅថ្នាក់ក្រោមជាតិទទួលបាននូវភាពស្របច្បាប់យ៉ាងទូលំទូលាយជាស្ថាប័ននយោបាយ។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ មធ្យម)* | ខ្ពស់ | ដោយសារតែការយឺតយ៉ាវនៃការអភិវឌ្ឍនូវមូលនិធិក្រុង ស្រុក ហេតុនេះ ភាពស្របច្បាប់នៃក្រុង ស្រុកក្នុងនាមជាស្ថាប័ននយោបាយបានជួបនូវបញ្ហាប្រឈម ហើយកិច្ចដំណើរការរៀនបណ្តើរៗអនុវត្តបណ្តើរក៏ពុំទាន់ត្រូវបានអនុវត្តឡើយ។ ការអភិវឌ្ឍសមត្ថភាពដ៏ទូលំទូលាយដល់គណៈអភិបាល មន្ត្រីរដ្ឋបាល និងសមាជិកក្រុមប្រឹក្សានឹងត្រូវបានបន្តអនុវត្ត។ |
| ២. សិទ្ធិអំណាច និងគណនេយ្យភាពរបស់ក្រុមប្រឹក្សាត្រូវបានបង្កើតឡើងនៅតាមរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖មធ្យម)* | ខ្ពស់ | ដោយសារតែការយឺតយ៉ាវនៃការអភិវឌ្ឍនូវមូលនិធិក្រុង ស្រុក បាននាំឲ្យសិទ្ធអំណាច និងគណនេយ្យភាពរបស់ក្រុង ស្រុកត្រូវមានការលំបាកក្នុងការរៀបចំបង្កើតឡើង។ ជំហានដំបូងនានានៃការអភិវឌ្ឍប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ដែលអាចបង្កើតនូវ គណនេយ្យភាព) និងវិធានផ្ទៃក្នុងរបស់ក្រុង ស្រុកត្រូវបានរៀបចំ។ ទោះជាយ៉ាងនេះក្តី ក៏សកម្មភាពទាំងពីរនេះនៅពុំទាន់ត្រូវបានរៀបចំបញ្ចប់ឡើយ។ |
| ៣. សមាជិកក្រុមប្រឹក្សាជាប់ឆ្នោតអាចធ្វើការជាមួយគ្នាបាន។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖មធ្យម)* | ទាប | ការសន្មតនេះពុំត្រូវបានបង្ហាញថាជាបញ្ហាទៀតឡើយ |
| ៤. យន្តការដើម្បីតម្លាភាពត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ និងមានទិន្នន័យដែលមានសុពលភាពគ្រប់គ្រាន់។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖មធ្យម)* | មធ្យម | មានទិន្នន័យជាច្រើនដែលអាចរកបាននៅក្នុងប្រព័ន្ធទិន្នន័យរបស់រដ្ឋាភិបាល ក៏ប៉ុន្តែព័ត៌មានទាំងនោះពុំទាន់ត្រូវបានរៀបចំឲ្យមានលក្ខណៈជាប្រព័ន្ធសម្រាប់ការផ្សព្វផ្សាយជូនប្រជាពលរដ្ឋឲ្យបានទូលំទូលាយនៅឡើយ។ ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្ត។ ផ្អែកលើផែនការយុទ្ធសាស្ត្រនេះ គម្រោងគណនេយ្យភាពសង្គមមួយកំពុងត្រូវបានរៀបចំតាក់តែង |

| ការសន្ទតនៃផអ៣ | កម្រិតនៃហានភ័យ | ដំណោះស្រាយនានា |
|---|---|---|
| | | ឡើង ដោយមានឧបករណ៍នានាដែលកំពុងស្ថិតនៅក្នុងការអនុវត្តសាកល្បង។ |
| ៥. សង្គមស៊ីវិល បណ្តាញសារព័ត៌មាន និងគ្រឹះស្ថានសិក្សាមានឱកាស និងមានសមត្ថភាពក្នុងការវិភាគ វាយតម្លៃ ពិនិត្យ និងរាយការណ៍អំពីការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ ទាប-មធ្យម)* | មធ្យម | នៅក្នុងគេហទំព័ររបស់គ.ជ.អ.ប មានផ្ទុកនូវព័ត៌មានជាច្រើន។ ទោះបីជាយ៉ាងនេះក្តី ក៏វេទិកា និងយន្តការនានាសម្រាប់ការពិភាក្សាអំពីព័ត៌មានទាំងនេះ និងសម្រាប់សម្របសម្រួលដល់ការពិភាក្សាផ្នែកគោលនយោបាយនៅក្នុងគ្រឹះស្ថានសិក្សានានាពុំទាន់ត្រូវបានជំរុញឲ្យបានខ្លាំងក្លានៅឡើង។ កិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវសម្រាប់ការអភិវឌ្ឍកម្ពុជា CDRI ក្នុងការរៀបចំ វេទិកាគោលនយោបាយនានាត្រូវបានចាប់ផ្តើម ក៏ប៉ុន្តែពុំទាន់ត្រូវបានរៀបចំបញ្ចប់នៅឡើយ។ |
| ៦. ពង្រីក ឬបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីតំណាងឱ្យក្រុមប្រឹក្សាទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ ទាប)* | ទាប | សមាគមក្រុមប្រឹក្សារាជធានី ខេត្តត្រូវបានរៀបចំបង្កើត និងចុះបញ្ជី។ ដោយឡែកសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់កំពុងត្រូវបានសម្របសម្រួលរៀបចំបង្កើតជាបណ្តើរ។ |
| **ការសន្ទតនានាដែលទាក់ទងនឹងការផ្តល់មូលនិធិ និងការរៀបចំបុគ្គលិក** | | |
| ១. ការលើកទឹកចិត្តត្រូវបានផ្តល់យ៉ាងគ្រប់គ្រាន់ដល់ការជ្រើសរើស និងការរក្សាបុគ្គលិកដែលមានសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតំបន់ដែលមិនមែនជាទីប្រជុំជន។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ ខ្ពស់)* | មធ្យម | ដោយសារប្រាក់បៀវត្សរបស់មន្ត្រីរដ្ឋាភិបាលនៅមានកម្រិតទាប និងប្រព័ន្ធប្រតិបត្តិការចំណាយអាទិភាពPOCត្រូវបានបញ្ចប់ អាស្រ័យហេតុនេះការសន្ទតនេះ នៅតែជាការសន្ទតដែលគួរឲ្យព្រួយបារម្ភណ៍នៅឡើយ។ |
| ២. មានចំនួនទីប្រឹក្សាជាតិ និងបុគ្គលិកកិច្ចសន្យាសមស្រប។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ ខ្ពស់)* | ទាប | ការសន្ទតនេះពុំត្រូវបានបង្ហាញឲ្យឃើញថាជាការសន្ទតដែលមានហានិភ័យទៀតឡើយ។ |
| ៣. មូលនិធិក្រុង ស្រុក ត្រូវបានបង្កើតឡើង។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ ទាប)* | ទាប | មូលនិធិក្រុង ស្រុកត្រូវបានបង្កើត |
| ៤. បែបផែននៃការផ្តល់មូលនិធិសម្រាប់ការវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ SNIFត្រូវបានបង្កើតឡើង។ *(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ មធ្យម)* | មធ្យម | មានការរីកចម្រើនតិចតួចក្នុងការរៀបចំយន្តការផ្តល់មូលនិធិសម្រាប់ការ វិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អាស្រ័យហេតុនេះ ការសន្ទតនេះ នៅតែជាការសន្ទតដែលមានហានិភ័យ |
| **ការសន្ទតនានាដែលទាក់ទងនឹងការរៀបចំកម្មវិធី** | | |
| ១. ការរៀបចំកម្មវិធីមានមហិច្ឆតាខ្ពស់ទាក់ទងនឹងវិសាលភាពគ្របដណ្តប់ ប៉ុន្តែដំណាក់កាលនៃការ | មធ្យម | មហិច្ឆិតានៃផអ៣ និងការយឺតយ៉ាវនៃការចាប់ផ្តើមអនុវត្តផអ៣ បាននាំឲ្យកម្រិតនៃហានិភ័យខ្ពស់។ |

| ការសន្មតនៃផអ៣ | កម្រិតនៃហានភ័យ | ដំណោះស្រាយនានា |
|---|---|---|
| អនុវត្តមានលក្ខណៈប្រាកដនិយម។<br>*(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ ខ្ពស់)* | | ការពន្យារពេល១ឆ្នាំនៃផអ៣នេះនឹងកាត់បន្ថយនូវហានិភ័យនេះ ក៏ប៉ុន្តែលទ្ធផលនានានៃផអ៣នៅតែត្រូវខិតខំអនុវត្តបញ្ចប់។ |
| ២. ការគាំទ្រពីដៃគូអភិវឌ្ឍន៍មាននិរន្តរភាព។<br>*(កម្រិតនៃហានិភ័យកំណត់ក្នុងផអ៣៖ ទាប)* | ទាប | ទោះបីការរពឹងទុកនៃការគាំទ្រយ៉ាងច្រើនពីគម្រោងការអភិវឌ្ឍរដ្ឋបាលមូលដ្ឋានរបស់ធនាគារពិភពលោកពុំត្រូវបានអនុម័តដែលបញ្ហានេះបានជះឥទ្ធិពលជាអវិជ្ជមានមកលើកម្មវិធីជាទូទៅ ក៏ការផ្តល់ការគាំទ្រពីដៃគូអភិវឌ្ឍថ្មីនានាបានកាត់បន្ថយនូវហានិភ័យនេះដែរ។ |